ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ចម្លើយទៅនឹងសំណួរ

# របស់អង្គការសហប្រជាជាតិ

# ស្តីពី

# អំពើហិង្សាលើកុមារ

២០០៥

# មាតិកា

ទំព័រ


**សេចក្តីផ្តើម** ........ ១

I. **ក្របខ័ណ្ឌការងារច្បាប់** ........ ១

- លិខិតូបករណ៍អន្តរជាតិ ស្តីពីសិទ្ធិមនុស្ស ........ ១
- បទបញ្ញាតិនៃច្បាប់ ស្តីពីអំពើហិង្សាលើកុមារ........ ២
- ស្ថាប័នតុលាការដែលមានភារកិច្ចក្នុងអំពើហិង្សាលើកុមារ........ ៩
- អាយុអប្បបរមាសម្រាប់ទំនាក់ទំនងផ្លូវភេទ ........ ៩
- ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ........ ១០
- រូបភាពអាសអាភាស និងព័ត៌មានមិនល្អ ........ ១០
- កាតព្វកិច្ចរាយការណ៍ទាក់ទងនឹងអំពើហិង្សាលើកុមារ ........ ១២
- នីតិវិធីបណ្តឹង ........ ១២

II. **ក្របខ័ណ្ឌការងារតាមគ្រឹះស្ថាន និងធនធានទាំងឡាយ ដើម្បីដោះស្រាយអំពើហិង្សាលើកុមារ** ........ ១៤

III. **តួនាទីរបស់សង្គមស៊ីវិលនៅក្នុងការដោះស្រាយអំពើហិង្សាលើកុមារ**........ ១៧

IV. **កុមារជាសកម្មជនក្នុងការដោះស្រាយអំពើហិង្សា**........ ១៩

V. **គោលនយោបាយ និងកម្មវិធីដើម្បីដោះស្រាយអំពើហិង្សាលើកុមារ**........ ២០

VI. **ការប្រមូលទិន្នន័យ វិភាគ និងការស្រាវជ្រាវ** ........ ២៤

VII. **ការយល់ដឹង ការទាក់ទាញមតិគាំទ្រ និងការបណ្តុះបណ្តាល**........ ២៤

## សេចក្តីផ្តើម

អំពើហិង្សាបានកើតឡើងនៅទូទាំងពិភពលោកទាំងក្នុងប្រទេសអភិវឌ្ឍ ឬ ប្រទេសកំពុងអភិវឌ្ឍ ទោះតូចក្តី ធំក្តី ជាពិសេសស្ត្រី និងកុមារជាជនទន់ខ្សោយ ត្រូវបានរងនូវផលប៉ះពាល់ច្រើនជាងគេ។ ប្រទេសកម្ពុជា ប្រកាន់យកនូវលទ្ធិប្រជាធិបតេយ្យ លើកកំពស់ការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិស្ត្រី និងកុមារ ដូចមានចែងច្បាស់ក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ស្របតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ និងអនុសញ្ញាស្តីពីការបំបាត់ចោលរាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ។

អំពើហិង្សាបានកើតឡើងក្នុងរយៈពេលសង្គ្រាម ជាពិសេសក្នុងរបបគ្រប់គ្រងដោយខ្មែរក្រហម១៩៧៥ ១៩៧៩ កុមាររាប់លាននាក់ត្រូវរងនូវអំពើហិង្សា។

ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ កុមារត្រូវបានជួយសង្គ្រោះជីវិត ត្រូវបានគាំទ្រដោយរដ្ឋាភិបាល និងត្រូវបានលើកតម្កើងដោយផ្តល់ឱកាសឱ្យក្លាយទៅជាកុមារឈានមុខ ប៉ុន្តែដោយពួកគេបានឆ្លងកាត់អតីតកាលដ៏ជូរចត់ក្នុងសង្គមមួយដែលបាត់បង់សីលធម៌ សុជីវធម៌ ជាកត្តាអកុសលមួយដែលបាននាំមកនូវការប្រព្រឹត្តិអំពើហិង្សា។

ក្រោយកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីបញ្ហាសន្តិភាពនៅកម្ពុជា ថ្ងៃទី២៣ តុលា ១៩៩១ ក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃប្រទេសកម្ពុជា (SNC) បានទទួលយកមកអនុវត្តនូវអនុសញ្ញាស្តីពីសិទ្ធិកុមារ នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩២។ បញ្ហារបស់កុមារត្រូវបានរាជរដ្ឋាភិបាលកាន់តែយកចិត្តទុកដាក់ គោលនយោបាយ ផែនការ និងកម្មវិធីជាតិ ត្រូវបានរៀបចំឡើងបន្ថែមទៀតជាបន្តបន្ទាប់ ដើម្បីការរស់រានមានជីវិត កិច្ចការពារ ការអភិវឌ្ឍ និងការរួមចំណែករបស់កុមារ។

## I. ក្របខ័ណ្ឌការងារច្បាប់

<u>**លិខិតូបករណ៍អន្តរជាតិ ស្តីពី សិទ្ធិមនុស្ស**</u>

***<u>សំណួរទី ១</u> : ចូរពិពណ៌នាអំពីការវិវត្តន៍ថ្មីៗដែលទាក់ទងនឹងអំពើហិង្សាលើកុមារ បន្ទាប់ពីប្រទេសអ្នកបានយល់ព្រមអនុវត្តលិខិតូបករណ៍អន្តរជាតិស្តីពីសិទ្ធិមនុស្ស រួមមាន អនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារជ្រើសរើស ពិធីសារ Palermo ឬ លិខិតូបករណ៍ថ្នាក់តំបន់ស្តីពីសិទ្ធិមនុស្ស។ ផ្តល់ព័ត៌មានលើករណីទាក់ទងនឹងអំពើហិង្សាលើកុមារ ដែលតុលាការប្រទេសអ្នកបានយកបទដ្ឋានអន្តរជាតិ ឬ ថ្នាក់តំបន់ ស្តីពីសិទ្ធិមនុស្សមកអនុវត្ត។***

***<u>ចម្លើយ</u>* :** កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារ (អ.ស.ក) នៅថ្ងៃទី១៥ តុលា ១៩៩២។ អ.ស.ក នេះ ត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកការជួញដូរមនុស្ស ជាកង្វល់ដ៏ចម្បងមួយ ស្របពេលជាមួយនឹងភាពក្រីក្រ និងភាពអវិជ្ជាដែលកំពុងតែកើតមាន។ ជាលទ្ធផល នៅឆ្នាំ១៩៩៥ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក.ក) ត្រូវបានបង្កើតឡើង។ ស្ថាប័នអន្តរក្រសួងនេះ មានភារកិច្ច លើកកម្ពស់ សម្របសម្រួល ពិនិត្យតាមដាន និងធ្វើរបាយការណ៍លើការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ។ ច្បាប់ស្តីពី ការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស ត្រូវបានអនុម័តដោយរដ្ឋសភា និងប្រកាសឱ្យប្រើក្នុង

ឆ្នាំ១៩៩៦។ ច្បាប់នេះ មានគោលបំណងប្រយុទ្ធប្រឆាំងនឹងការកេងប្រវ័ញ្ចផ្លូវភេទ និងអំពើអនាចារលើមនុស្ស រួមទាំងកុមារផង។ ដើម្បីជំរុញប្រសិទ្ធភាពនៃការអនុវត្តច្បាប់ប្រឆាំងការជួញដូរមនុស្ស រាជរដ្ឋាភិបាលបានបង្កើតស្ថាប័នជំនាញជាច្រើននៅតាមក្រសួងផ្សេងៗ ដូចជាគណៈកម្មការអន្តរក្រសួងបង្ក្រាបការធ្វើអាជីវកម្ម បញ្ចាំង និងការលក់កាសែតវីដេអូអាសអាភាស (សេចក្តីសម្រេចលេខ១៤ ចុះថ្ងៃទី២៩ កុម្ភៈ ២000) និងបានបង្កើតនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន (AHTJP) នៅក្រសួងមហាផ្ទៃ (ឆ្នាំ២00២)។

នៅថ្ងៃទី៦ មេសា ២000 ផែនការសកម្មភាពជាតិប្រាំឆ្នាំប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ត្រូវបានរាជរដ្ឋាភិបាលប្រកាសអោយប្រើជាផ្លូវការ។

នៅក្នុងឆ្នាំ២00២ ពិធីសារជ្រើសរើសរបស់ អ.ស.ក ស្តីពីការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ និងអំពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារនិងការផ្សព្វផ្សាយរូបភាពអាសអាភាសរបស់កុមារ ត្រូវបានផ្តល់សច្ចាប័ន។

ប្រភេទអំពើហិង្សាផ្សេងៗទៀតលើកុមារ ត្រូវបានដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ជាច្រើន ដែលកំពុងតែរង់ចាំការអនុម័តពីរដ្ឋសភា និងព្រឹទ្ធសភា។ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ត្រូវបានអនុម័តនៅក្នុងឆ្នាំ ២00៥ នេះ។ សេចក្តីព្រាងច្បាប់ស្តីពីវិស័យអប់រំត្រូវបាន សង្ឃឹមថានឹងត្រូវអនុម័តក្នុងពេលឆាប់ៗនេះ។ សេចក្តីព្រាងក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ហើយនិងសេចក្តីព្រាងច្បាប់ថ្មីមួយស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីរួចហើយ។ សេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជន កំពុងស្ថិតនៅក្នុងការពិនិត្យដោយអនុគណៈកម្មការតាក់តែងច្បាប់របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។

សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីមាត្រា ២២៣២-១ បានចែងអំពីការផ្តន្ទាទោសដល់អ្នកប្រព្រឹត្តអំពើអាសទៅលើអ្នកដទៃ និងសេចក្តីព្រាងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មាត្រា ៤0 មានចែងពីការផ្តន្ទាទោសដល់ជនដែលចែកចាយ លក់ ជួល ឬដាក់តាំង បញ្ចាំង បង្ហាញ កាន់កាប់ ដឹកជញ្ជូន នាំចេញចូល និងផលិតរូបភាព និងសម្ភារៈអាសអាភាស។

កម្ពុជាបានផ្តល់សច្ចាប័នលើសន្ធិសញ្ញាអន្តរជាតិជាច្រើន ប៉ុន្តែដោយសារនៅកម្ពុជាមិនទាន់មានប្រព័ន្ធយុត្តិធម៌ដាច់ដោយឡែកសម្រាប់កុមារ ដូច្នេះការប្រើប្រាស់សន្ធិសញ្ញាអន្តរជាតិក្នុងប្រព័ន្ធតុលាការនៅមានកម្រិត។ ក្នុងករណីគោលការណ៍ណាដែលពុំមានចែងនៅក្នុងច្បាប់កម្ពុជា ហើយមានចែងក្នុង អ.ស.ក តុលាការនឹងលើកយកគោលការណ៍នោះមកប្រើក្នុងការដោះស្រាយរឿងក្តី។ ឧទាហរណ៍ តុលាការខេត្តសៀមរាបបានលើកយកមាត្រា ៣៧ និង៤0 នៃ អ.ស.ក ធ្វើជាសំអាងនៃស្ថានសម្រាលដើម្បីផ្តន្ទាទោសជនល្មើសជាអនីតិជន។

**បទបញ្ញត្តិនៃច្បាប់ ស្តីពីអំពើហិង្សាលើកុមារ**

***សំណួរទី ២ : ចូរពិពណ៌នាអំពីទម្រង់អំពើហិង្សាលើកុមារដែលមាននៅក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ ឬបទបញ្ជាផ្សេងៗទៀត និងទំនៀមទម្លាប់ បើសិនជាមាន។***

***<u>ចម្លើយ</u>*** ៖ រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ៣១ និងមាត្រា ៤៨ ទទួលស្គាល់ និងគោរពសិទ្ធិមនុស្សទូទៅ និងសិទ្ធិកុមារដែលមានចែងនៅក្នុង អ.ស.ក។ ដូច្នេះ អំពើទាំងឡាយណាដែលត្រូវបានចាត់ទុកជាអំពើហិង្សាលើកុមារនៅក្នុង អ.ស.ក អាចចាត់ទុកដូចគ្នានៅក្នុងច្បាប់កម្ពុជា។ ការប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាលើកុមារ និងការដាក់ទណ្ឌកម្មជនល្មើសមានពាសពេញនៅក្នុងច្បាប់ផ្សេងៗរបស់ព្រះរាជាណាចក្រកម្ពុជា ទោះបីមិនមានកម្រងច្បាប់មួយដោយឡែកតែឯងក៏ ដោយ។

ផ្អែកតាមនិយមន័យនៃការសិក្សាស្រាវជ្រាវអំពីអំពើហិង្សាលើកុមាររបស់អង្គការសហប្រជាជាតិ ការរំលោភសេពសន្ថវៈ ការគំរាមកំហែងផ្លូវភេទ និងស្មារតី ទណ្ឌកម្មលើរូបរាងកាយ ការបៀតបៀនកេរ្តិ៍ខ្មាស់ អំពើអាស ការវាយដំ ការឱ្យធ្វើការហួសកម្លាំង អំពើអនាចារ ការកេងប្រវ័ញ្ចផ្លូវភេទ និងរូបភាពអាសអាភាស អាចចាត់ទុកជាអំពើហិង្សាលើកុមារ។ ចំណែកឯប្រព័ន្ធច្បាប់កម្ពុជាវិញ អំពើល្មើសដែលមានចែងក្នុងការស្រាវជ្រាវនេះ មានចែងនៅក្នុងក្រមព្រហ្មទណ្ឌសព្វគ្រប់អស់ហើយ ក្រោមរូបភាពជាបទល្មើសព្រហ្មទណ្ឌ។

យោងតាមច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ ត្រូវចាត់ទុកជាអំពើហិង្សាក្នុងគ្រួសារ៖

- ការប៉ះពាល់ដល់ជីវិត
- ការប៉ះពាល់ដល់បូរណភាពរូបរាងកាយ
- ការធ្វើទារុណកម្ម ការធ្វើអំពើឃោរឃៅ
- ការឈ្លានពានខាងផ្លូវភេទ។

តាមទំនៀមទម្លាប់កម្ពុជាមិនបានទូន្មានឱ្យប្រព្រឹត្តអំពើហិង្សាលើកុមារទេ។

***<u>សំណួរទី៣</u> ៖ ចូរផ្តល់ភាពលម្អិតលើច្បាប់ពិសេសស្តីពី ៖***

- ***ការទប់ស្កាត់រាល់ទម្រង់នៃអំពើហិង្សាលើរូបរាងកាយ ផ្លូវភេទ និងបញ្ហាស្មារតី ការធ្វើឱ្យរបួស ឬការរំលោភបំពាន ការមិនយកចិត្តទុកដាក់ ឬការមិនយកចិត្តទុកដាក់ថែទាំ និង ការរំលោភផ្លូវភេទ***
- ***កិច្ចការពារកុមារពីរាល់ទម្រង់នៃអំពើហិង្សា***
- ***ការធ្វើឱ្យប្រសើរឡើងវិញ រួមមាន សំណងសម្រាប់កុមាររងគ្រោះដោយអំពើហិង្សា***
- ***ទណ្ឌកម្មសម្រាប់ជនល្មើសដែលប្រព្រឹត្តអំពើហិង្សាលើកុមារ***
- ***សមាហរណកម្ម និងការស្តារសម្បទាកុមាររងគ្រោះដោយអំពើហិង្សា***

***<u>ចម្លើយ</u>*** ៖ ច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល (អ៊ុនតាក់) ចុះថ្ងៃទី១០ កញ្ញា ១៩៩២ ដែលកំពុងអនុវត្តនៅកម្ពុជា មានចែងយ៉ាងច្បាស់អំពីបទល្មើសដែលទាក់ទងទៅនឹងអំពើហិង្សាលើកុមារ មានជាអាទិ៍ ការបង្កឱ្យមានរបួសស្នាម ការបៀតបៀនកេរ្តិ៍ខ្មាស់ ការប្រព្រឹត្តអំពើអនាចារ។ល។ ក្រៅពីនេះ នៅមានច្បាប់ជាច្រើនទៀតដែលបានឆ្លើយតបទៅនឹងសំណួរទី៣ខាងលើ ដូចជា៖

- រដ្ឋធម្មនុញ្ញ
- អនុសញ្ញាផ្សេងៗ

- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ចុះថ្ងៃទី ២៦ កក្កដា ១៩៨៩
- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ៨ មិនា ១៩៩៣
- ច្បាប់ស្តីពីរបបសារព័ត៌មាន ចុះថ្ងៃទី ១ កញ្ញា ១៩៩៥
- ច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស ចុះថ្ងៃទី១៦ មករា ១៩៩៦
- ច្បាប់ស្តីពីការងារ ចុះថ្ងៃទី ១៣ មិនា ១៩៩៧
- ច្បាប់ស្តីពីការរំលូតកូន ចុះថ្ងៃទី ១២ វិច្ឆិកា ១៩៩៧
- ច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ចុះថ្ងៃទី១៩ វិច្ឆិកា ២០០១ ដោយមានបញ្ចូលផងនូវបទល្មើសរំលោភសេពសន្ថវៈ
- ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៥ ។

ទន្ទឹមនឹងនេះ នៅមានសារាចរណែនាំមួយចំនួនទៀតរបស់រាជរដ្ឋាភិបាល និងក្រសួងមានសមត្ថកិច្ច ជារួមមានសារាចរ ស្តីពីការគ្រប់គ្រងភ្នាក់ងារ និងក្រុមហ៊ុនប្រកបអាជីវកម្ម ទេសចរណ៍ ភោជនីយដ្ឋាន រង្គសាល ខារ៉ាអូខេ និងសណ្ឋាគារ មិនឱ្យមានសកម្មភាពជួញដូរគ្រឿងញៀន ជួញដូរផ្លូវភេទលើកុមារ ប្រើប្រាស់កាសែតវីដេអូដែលគ្មានទិដ្ឋាការ នាំកុមារចូលក្នុងសណ្ឋាគារដែលមិនមានលក្ខណៈជាគ្រួសារ ។ មិនអនុញ្ញាតឱ្យស្ថានីយទូរទស្សន៍បញ្ចាំងកម្មវិធីណា ដែលអាចធ្វើឱ្យប៉ះពាល់ដល់ស្មារតី អារម្មណ៍ ទឹកចិត្ត និងសុខភាពកុមារ ។ល។

យោងតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី៨ មិនា ១៩៩៣ បុគ្គល ឬកុមាររងគ្រោះដោយអំពើល្មើសអាចដាក់ពាក្យបណ្តឹងជាមួយការចោទប្រកាន់របស់ព្រះរាជអាជ្ញា ដើម្បីទាមទារសំណងជម្ងឺចិត្ត ( មាត្រា៩) ។

ជាទូទៅ អំពើហិង្សាលើកុមារត្រូវបានផ្តន្ទាទោសយ៉ាងធ្ងន់ តាមរយៈការដាក់ពន្ធនាគារ សំណងរដ្ឋប្បវេណី និងអនុទោសមួយចំនួនទៀត ដោយយោងទៅតាមប្រភេទនៃបទល្មើស ។ ចំពោះបទល្មើសដែលពាក់ព័ន្ធនឹងការជួញដូរមនុស្ស ជនល្មើសត្រូវបានផ្តន្ទាទោសដោយច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស ។

ចំពោះការងារសមាហរណកម្ម និងស្តារនីតិសម្បទាកុមាររងគ្រោះដោយអំពើហិង្សា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានប្រកាសលេខ ៣០៣ ចុះថ្ងៃទី១៥ វិច្ឆិកា ២០០០ ស្តីពីការបង្កើតមជ្ឈមណ្ឌលយុវនីតិសម្បទាទទួលយកកុមារទាំងនោះដើម្បីអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្មទៅក្នុងគ្រួសារ និងសហគមន៍វិញ ។

***សំណួរទី៤*** ***: ចូរបង្ហាញថា តើមានបញ្ញត្តិច្បាប់ពិសេសណាមួយដែលនិយាយពីរាល់ទម្រង់អំពើហិង្សា រួមមានអំពើហិង្សាលើរូបរាងកាយ ផ្លូវភេទ និងអារម្មណ៍ ការធ្វើឱ្យរបួស ឬការរំលោភបំពាន ការមិនយកចិត្តទុកដាក់ ឬការមិនយកចិត្តទុកដាក់ថែទាំ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ដែលប្រព្រឹត្តទៅនៅ :***

- ***ក្នុងគ្រួសារ ឬ ផ្ទះ***

- *ក្នុងសាលារៀន និងការថែទាំ ការអប់រំនៅមត្តេយ្យសាលា (ទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ទាំងរដ្ឋ និងឯកជន)*
- *សាលាយោធា*
- *គ្រឹះស្ថានផ្តល់ការថែទាំ ស្នាក់នៅ សុខភាព និងសុខភាពផ្លូវចិត្ត*
- *បរិបទច្បាប់ និងសណ្តាប់ធ្នាប់សាធារណៈ រាប់ទាំងកន្លែងឃុំខ្លួនបណ្តោះអាសន្ន ឬ ពន្ធនាគារ*
- *ភាពនៅជិតខាងគ្នា នៅតាមផ្លូវ និងសហគមន៍ រាប់ទាំងទីជនបទ*
- *កន្លែងធ្វើការ (រដ្ឋ និងឯកជន)*
- *កីឡា និងកន្លែងលេងកីឡា*

**ចម្លើយ :** តាមប្រពៃណី ទំនៀមទម្លាប់បុរាណរបស់ប្រជាជនកម្ពុជា បើកុមារមានការខុសឆ្គង មាតាបិតា ឬ អាណាព្យាបាល លោកគ្រូ អ្នកគ្រូ ត្រូវអនុវត្តតាមច្បាប់ និងយកការអប់រំជាមូលដ្ឋាន។

- **អំពើហិង្សានៅក្នុងគ្រួសារ និងនៅតាមផ្ទះ :**

ដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ព្រះរាជាណាចក្រកម្ពុជាបានយកច្បាប់មួយចំនួនមកអនុវត្ត :

- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ១៩៨៩ :

  - មាត្រា ១១៦ បានចែងអំពីឪពុកម្តាយ មិនត្រូវធ្វើបាបកូនរបស់ខ្លួន។

  - ផ្នែកទី៦ មាត្រា ១១៩ ដល់ ១២២ បានចែងអំពីការដកហូតអំណាចមេបា ក្នុងករណីបង្ខំឱ្យកូនប្រព្រឹត្តល្មើសប៉ះពាល់ដល់សង្គម វាយធ្វើបាបកូន ឬ ប្រព្រឹត្តផ្ទុយពីសីលធម៌ដែលមានឥទ្ធិពលអាក្រក់ដល់កូន។

- ច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល (UNTAC) អាចយកមកអនុវត្ត ដើម្បីដាក់ទណ្ឌកម្មលើឪពុកម្តាយ។
- ច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ លក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស ចុះថ្ងៃទី១៦ មករា ១៩៩៦។
- ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ចុះថ្ងៃទី ២៤ តុលា ឆ្នាំ២០០៥។

- **អំពើហិង្សានៅតាមសាលារៀនៈ**

ក្រសួងអប់រំ យុវជន និងកីឡា មានសេចក្តីណែនាំស្តីពី **បទបញ្ជាផ្ទៃក្នុង** នៅក្នុងសាលាបឋមសិក្សា និងមធ្យមសិក្សា។ ការដាក់វិន័យលើសិស្ស គ្រូអាចធ្វើការព្រមានដោយផ្ទាល់មាត់ បង្គាប់សិស្សឱ្យសរសេរច្រើនឃ្លា សរសេរប្រភេទទណ្ឌកម្មនៅក្នុងសៀវភៅសិក្ខាគារិករបស់សិស្ស (មាត្រា១៧)។ គ្រូមិនត្រូវបានអនុញ្ញាតឱ្យមានការធ្វើទណ្ឌកម្មលើរូបរាង កាយសិស្សឡើយ (មាត្រា ១៨)។

- **អំពើហិង្សានៅតាមសាលាយោធាៈ**

នៅកម្ពុជាពុំមានកុមារជាសិស្សយោធាទេ។

- **អំពើហិង្សាតាមគ្រឹះស្ថានផ្តល់ការថែទាំ ស្នាក់នៅ សុខភាព និងសុខភាពផ្លូវចិត្តៈ**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានបទបញ្ជាផ្ទៃក្នុងសម្រាប់មជ្ឈមណ្ឌលយុវនីតិសម្បទា និងមជ្ឈមណ្ឌលកុមារកំព្រា ដើម្បីឱ្យមានវិន័យនៅក្នុងមណ្ឌល និងហាមឃាត់ការធ្វើអំពើហិង្សាលើកុមារ។ ដោយឡែកមជ្ឈមណ្ឌលរបស់អង្គការមិនមែនរដ្ឋាភិបាល ក៏មានបទបញ្ជាផ្ទៃក្នុងប្រហាក់ប្រហែលគ្នានេះដែរ។ ទន្ទឹមនេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា កំពុងរៀបចំគោលនយោបាយ ស្តីពីការថែទាំជំនួស និងស្តង់ដាអប្បបរមានៃការថែទាំជំនួសចំពោះកុមារ ដើម្បីដាក់ឱ្យមជ្ឈមណ្ឌលទាំងអស់ អនុវត្តការគោរពសិទ្ធិជាមូលដ្ឋានរបស់កុមារឱ្យបានល្អប្រសើរ។

- **បរិបទច្បាប់ និងសណ្តាប់ធ្នាប់សាធារណៈ រាប់ទាំងកន្លែងឃុំខ្លួនបណ្តោះអាសន្ន ឬ ពន្ធនាគារៈ**

ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្មទៅលើជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវហាមឃាត់មិនឱ្យធ្វើឡើយ។ អ្នកដៃដល់ អ្នករួមប្រព្រឹត្ត និងអ្នកផ្សំគំនិតត្រូវទទួលទោសតាមច្បាប់ (មាត្រា៣៨ វាក្យខណ្ឌ២ រដ្ឋធម្មនុញ្ញ)។ យោងតាមច្បាប់ព្រហ្មទណ្ឌក្នុងសម័យអន្តរកាល គ្មានជនជាប់ឃុំណាម្នាក់ត្រូវទទួលរងទណ្ឌកម្ម ឬការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅ អមនុស្សធម៌ ឬនាំឱ្យបាត់បង់តម្លៃជាមនុស្ស ឬក៏ត្រូវគេវាយដំ និងធ្វើទារុណកម្មឡើយ។ ជនជាប់ឃុំម្នាក់ៗត្រូវបានទទួលការថែទាំតាមវិធីពេទ្យត្រឹមត្រូវ។ អ្នកទោសទាំងឡាយមិនត្រូវបានគេដាក់ច្រវាក់ ឬដាក់ឱ្យនៅឯកោម្នាក់ឯងទេ ទោះស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្នក្តី ឬត្រូវបានកាត់ទោសរួចហើយក្តី។ ទោះក្នុងករណីណាក៏ដោយ គ្រួសារអ្នកជាប់ឃុំ ឬគ្រួសារអ្នកទោសមិនត្រូវមានគេយាយី ដោយសារតែការប្រព្រឹត្តរបស់ជននោះឡើយ (មាត្រា១២)។ គ្រប់ភ្នាក់ងារសាធារណៈ រួមទាំងភ្នាក់ងារនគរបាល និងយោធិន ដែលរំលោភដោយមិនរុញរាទៅលើសិទ្ធិបូរណភាពបុគ្គល និងភាពមិនអាចរំលោភបាននៃលំនៅដ្ឋាន ដែលត្រូវបានការពារដោយបទប្បញ្ញត្តិនេះ នឹងត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៥ឆ្នាំ (មាត្រា៥៧)។ មាត្រា១៤-៥ នៃច្បាប់ព្រហ្មទណ្ឌក្នុងសម័យអន្តរកាល ក៏មិនអនុញ្ញាតឱ្យមានការដាក់ឃុំបណ្តោះអាសន្នទៅលើកុមារអាយុក្រោម ១៣ឆ្នាំដែរ។ ចំពោះកុមារដែលមានអាយុពី ១៣ ដល់ ១៨ឆ្នាំ ការឃុំខ្លួនបណ្តោះអាសន្នត្រូវមានរយៈពេលត្រឹមតែ ១ខែ ហើយអាចពន្យាបានត្រឹម ១ខែទៀតប៉ុណ្ណោះ។

- **ភាពជិតខាងគ្នា នៅតាមផ្លូវ និងសហគមន៍ រាប់ទាំងទីជនបទៈ**

នៅព្រះរាជាណាចក្រកម្ពុជា រាល់អំពើហិង្សាលើកុមារដែលកើតនៅទីណាក៏ដោយ ក៏ត្រូវបានកំណត់នៅក្នុងច្បាប់ៈ

- ច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល បានកំណត់អំពីអំពើ :
    - បង្ករបួសស្នាម (មាត្រា ៤១)
    - អំពើបៀតបៀនកេរ្តិ៍ខ្មាស់ (មាត្រា ៤២)។
- ច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស មានកំណត់អំពីអំពើ :
    - ពេស្យាកម្មលើកុមារ
    - អនាចារលើកុមារ

- ច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ មាត្រា ៥-២ បានកំណត់អំពីអំពើ : ការរំលោភសេពសន្ថវៈដោយការគំរាមកំហែងទៅលើអនីតិជនអាយុតិចជាង ១៤ឆ្នាំ ជនល្មើសត្រូវទទួលទណ្ឌកម្មដាក់ពន្ធនាគារពី ១៥ ទៅ ២០ឆ្នាំ ។

- **អំពើហិង្សានៅតាមទីកន្លែងធ្វើការងារៈ**

- ច្បាប់ស្តីពីការងារ

- មាត្រា ១៧២ : មានចែងហាមឃាត់តឹងរឹងចំពោះការរំលោភផ្លូវភេទគ្រប់ទ្រង់ទ្រាយទាំងអស់ ។

- មាត្រា ១៧៧ វាក្យខណ្ឌ ៤ អនីតិជនក្រោម ១៥ឆ្នាំ មិនត្រូវបានអនុញ្ញាតឱ្យធ្វើការទេ។ អនីតិជនមានអាយុចាប់ពី ១៥ ទៅ ១៨ឆ្នាំ អាចធ្វើការដែលមិនប៉ះពាល់ដល់សុវត្ថិភាព សុខភាព ឬ ស្មារតីរបស់កុមារ ។ ផ្ទុយមកវិញ អនីតិជនពី ១២ ទៅ ១៥ឆ្នាំ អាចជួលឱ្យធ្វើការងារបាន បើសិនជាការងារនោះមិនប៉ះពាល់ដល់ការអភិវឌ្ឍ ការសិក្សា សុខភាព ស្មារតី រាងកាយ របស់កុមារ ។

- **អំពើហិង្សាក្នុងកីឡា** : មាត្រា ៤៨-២ រដ្ឋធម្មនុញ្ញចែងថា : *"រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងការរៀនសូត្រ ឬ ដែលនាំឱ្យអន្តរាយដល់សុខភាព ឬ សុខុមាលភាពរបស់កុមារ"*។ បទប្បញ្ញត្តិរបស់ក្រសួងអប់រំ យុវជន និងកីឡា បានអនុញ្ញាតឱ្យកុមារចូលប្រកួតទៅតាមកម្រិត។ ដូចជា : សិស្សបឋមប្រកួតជាមួយសិស្សបឋម សិស្សមធ្យមប្រកួតជាមួយសិស្សមធ្យម ។ល។ នៅព្រះរាជាណាចក្រកម្ពុជា ច្បាប់មិនមានចែងអំពីការអនុញ្ញាត្តិឱ្យកុមារចូលរួមក្នុងកីឡាជាអាជីពទេ ។

***<u>សំណួរទី៥</u> : ចូរបង្ហាញថាទណ្ឌកម្មលើរូបរាងកាយកុមារនៅគ្រប់ករណីទាំងអស់ រួមមាននៅក្នុងគ្រួសារ ត្រូវបានហាមឃាត់យ៉ាងច្បាស់លាស់ដោយប្រព័ន្ធច្បាប់របស់ប្រទេសអ្នក ។ ចូរផ្តល់ព័ត៌មានលម្អិត ស្តីពី កិច្ចការពារដោយច្បាប់ទៅលើអ្នកដែលធ្វើទណ្ឌកម្មលើរូបរាងកាយកុមារ រាប់ទាំងនៅក្នុងគ្រួសារ ។ ចូរផ្តល់ព័ត៌មាន ស្តីពីទោសទណ្ឌទៅលើអ្នកដែលធ្វើទណ្ឌកម្មលើរូបរាងកាយកុមារ រាប់ទាំងក្នុងគ្រួសារ ។***

***<u>ចម្លើយ</u> :***

១-ប្រព័ន្ធច្បាប់កម្ពុជាបានហាមឃាត់ មិនឱ្យមានធ្វើទណ្ឌកម្មលើរូបរាងកាយនៅគ្រប់ករណីទាំងអស់ ដូចបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ :

- មាត្រា ៣៨-១ : ច្បាប់រ៉ាប់រងមិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ ។

- មាត្រា៣៨-៤: ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវហាមឃាត់មិនឱ្យធ្វើឡើយ។ អ្នកដៃដល់ អ្នករួមប្រព្រឹត្ត និងអ្នកសម គំនិតត្រូវទទួលទោសតាមច្បាប់ ។

២-ជាគោលការណ៍ច្បាប់នៅកម្ពុជាពុំបានការពារអ្នកដែលធ្វើទណ្ឌកម្មលើរូបរាងកាយកុមារនោះឡើយ ។ ប៉ុន្តែច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះបានចែងថា ការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌ មិនអាចធ្វើបានឡើយ បើមានសំណើពីជនរងគ្រោះជានីតិជន ដោយបទល្មើសនោះ ជាបទមជ្ឈិមស្រាល ឬ បទលហុ ( មាត្រា ៣៦) ។

៣-នៅប្រទេសកម្ពុជាបច្ចុប្បន្ន ទោសទណ្ឌដែលដាក់ទៅលើអ្នកធ្វើទណ្ឌកម្មលើរូបរាងកាយកុមារ គឺអនុលោមទៅតាមអំពើ និងព្យសនកម្ម ដែលបានកើតឡើងពីអំពើនេះ ដូចបានកំណត់ក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា៤១ :

- ជនណាវាយតប់បណ្តាលឱ្យមានរបួស ដែលនាំឱ្យពិការជាអចិន្ត្រៃយ៍ ឬពិការបណ្តោះអាសន្នក្នុងរយៈពេលលើសពី ៦ខែ ដោយចេតនា ត្រូវមានទោសពីបទបង្ករបួសដោយចេតនា ហើយត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៥ឆ្នាំ។
- បើពិការភាពបណ្តោះអាសន្នតិចជាង៦ខែ ត្រូវផ្តន្ទាទោសដាក់គុកជននោះពី៦ខែ ដល់ ២ឆ្នាំ។
- បើគ្មានពិការភាពទេ ទោសដែលត្រូវកំណត់ផ្តន្ទាគឺដាក់គុកពី២ខែ ទៅ ១ឆ្នាំ។
- បើការវាយតប់នោះធ្វើឡើងដោយប្រើអាវុធប្រភេទណាមួយ កម្រិតទោសត្រូវទ្វេមួយជាពីរ។

***<u>សំណួរទី៦</u> : ចូរផ្តល់ព័ត៌មាន ថាតើក្រមព្រហ្មទណ្ឌអនុញ្ញាតឱ្យមានការដាក់ទណ្ឌកម្មលើរូបរាងកាយ និង/ឬទោសប្រហារជីវិត ទៅលើបទល្មើសដែលប្រព្រឹត្តដោយជនល្មើសដែលនៅក្រោមអាយុ ១៨ឆ្នាំ ឬទេ។***

***<u>ចម្លើយ</u>*** : ច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល (អ៊ុនតាក់) នៅព្រះរាជាណាចក្រកម្ពុជាមិនអនុញ្ញាតឱ្យមានការដាក់ទណ្ឌកម្មលើរូបរាងកាយ និង/ឬទោសប្រហារជីវិតឡើយ ទោះបទល្មើសនោះ ប្រព្រឹត្តដោយនីតិជន ឬអនីតិជនក៏ដោយ។ រដ្ឋធម្មនុញ្ញ មាត្រា ៣២ បានលុបចោលទោសប្រហារជីវិតតាំងពីឆ្នាំ ១៩៩៣។

***<u>សំណួរទី៧</u>: ចូរផ្តល់ព័ត៌មានលម្អិត ថាតើការបំបាក់ស្មារតី និងការរំលោភបំពានខាងផ្លូវភេទ (នៅក្នុងមជ្ឈដ្ឋានការងារ) ត្រូវបាននិយាយយ៉ាងច្បាស់លាស់ដោយច្បាប់ឬទេ។***

***<u>ចម្លើយ</u>*** : ករណីបំបាក់ស្មារតី និងករណីរំលោភបំពានផ្លូវភេទ ត្រូវបានចែងយ៉ាងច្បាស់ដោយច្បាប់។ ច្បាប់ត្រូវតែបានយកទៅអនុវត្តចំពោះគ្រប់ករណីដូចដែលបានកំណត់នៅក្នុងនិយមន័យនៃអំពើទាំងនេះ ទោះជាអំពើបែបនេះត្រូវបានប្រព្រឹត្តនៅក្នុងមជ្ឈដ្ឋានការងារក៏ដោយ។

ច្បាប់ស្តីពីការងារ បានហាមឃាត់យ៉ាងតឹងរឹងចំពោះការរំលោភបំពានខាងផ្លូវភេទគ្រប់ទ្រង់ទ្រាយទាំងអស់ (មាត្រា ១៧២)។ អំពើបៀតបៀនដល់កេរ្តិ៍ខ្មាស់ និងអំពើរំលោភសេពសន្ថវៈដែលត្រូវបានប្រព្រឹត្តដោយនិយោជក ឬជនណាម្នាក់ទៀតនៅទីកន្លែងធ្វើការនឹងត្រូវផ្តន្ទាទោស។

អំពើបៀតបៀនដល់កេរ្តិ៍ខ្មាស់ (មាត្រ ៤២ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ឆ្នាំ ១៩៩២)។

អំពើរំលោភសេពសន្ថវៈ ត្រូវបានចែងដោយមាត្រា ៣៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ហើយមាត្រានេះត្រូវបានកែសម្រួលឱ្យកាន់តែមានប្រសិទ្ធភាពដោយមាត្រា ៥ ច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ឆ្នាំ ២០០១។

***<u>សំណួរទី៨</u>: ចូរផ្តល់ព័ត៌មាន ថាតើច្បាប់និយាយយ៉ាងដូចម្តេចពីការអនុវត្តតាមប្រពៃណីដោយហិង្សា ឬមិនល្អសម្រាប់ជនរងគ្រោះ រាប់បញ្ចូលទាំងការវះកាត់ប្រដាប់ភេទស្ត្រី ការឱ្យកុមាររៀបការ ឬបទល្មើសទាក់ទងនឹងកិត្តិយស។***

***<u>ចម្លើយ</u>*** : ប្រពៃណីខ្មែរមិនមានការកាត់អវៈយវៈភេទនារី និងបទល្មើសទាក់ទងនឹងកិត្តិយស (Honor Crime) នោះទេ។ ជាគោលការណ៏នៅកម្ពុជា ច្បាប់មិនអនុញ្ញាតឱ្យកុមាររៀបការទេ។

***<u>សំណួរទី៩</u> : ចូរផ្ដល់ព័ត៌មាន ស្ដីពីការអនុវត្តច្បាប់ដោយឡែកទាក់ទងនឹងរាល់ទម្រង់អំពើហិង្សាលើកុមារ ដែលមិនមែនជាប្រជាពលរដ្ឋ និងដែលគ្មានស្រុកទេស រាប់ទាំងអ្នកសុំសិទ្ធិជ្រកកោន និងកុមារ ដែលត្រូវបានយកចេញពីកន្លែងមួយទៅកន្លែងមួយ ។ បើសិនជាវិធានពិសេសមិនអនុវត្តទៅលើកុមារទាំងអស់នោះទេ ចូរផ្ដល់ព័ត៌មានលម្អិតស្ដីពីការការពារកុមារទាំងអស់នោះ ។***

***<u>ចម្លើយ</u>*** : នៅកម្ពុជាមិនបែងចែកជនបរទេស ឬជនភៀសខ្លួន និងពលរដ្ឋក្នុងការអនុវត្តច្បាប់ប្រឆាំងអំពើហិង្សានោះឡើយ ។

***<u>សំណួរទី១០</u> : ចូរផ្ដល់ព័ត៌មានថា តើនិយមន័យនៃអំពើហិង្សាប្រែប្រួលឬអត់ ដោយយោងទៅតាមៈ***

***- ភេទ ឬការតម្រង់ទិសនៃភេទរបស់ជនរងគ្រោះ និង ឬជនល្មើស***

***- អាយុរបស់ជនរងគ្រោះ និង ឬជនល្មើស***

***- ទំនាក់ទំនងរវាងជនរងគ្រោះ និងជនល្មើស រាប់ទាំងទារកឃាត អំពើហិង្សាផ្លូវភេទក្នុងអាពាហ៍ពិពាហ៍សន្ធការ និងការលោភផ្លូវភេទក្នុងគ្រួសារ និងការធ្វើទោសលើផ្លូវចិត្ត ។***

***<u>ចម្លើយ</u>*** : ជាគោលការណ៍មិនមានការប្រែប្រួលទេ ។

***<u>សំណួរទី១១</u> : ចូរផ្ដល់ព័ត៌មានទាក់ទងនឹងការពិនិត្យឡើងវិញនូវក្របខ័ណ្ឌច្បាប់ ដើម្បីឆ្លើយតបទៅនឹងអំពើហិង្សាលើកុមារ ។***

***<u>ចម្លើយ</u>*** :

- ដើម្បីឆ្លើយតបអំពើហិង្សាលើកុមារ សេចក្ដីព្រាងក្រមព្រហ្មទណ្ឌថ្មី បានចែងនូវប្រភេទបទល្មើសជាច្រើនអំពីអំពើហិង្សាលើកុមារ ។

- ច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ត្រូវបានអនុម័តនៅឆ្នាំ ២០០៥ ។

***<u>សំណួរទី១២</u> : ចូរផ្ដល់ព័ត៌មាន ស្ដីពីការសិក្សា និងការស្ទង់មតិដែលបានធ្វើឡើង ដើម្បីវាយតម្លៃលើឧបសគ្គនៃវិធានការច្បាប់ដើម្បីឆ្លើយតបទៅនឹងអំពើហិង្សាលើកុមារ ។***

***<u>ចម្លើយ</u>*** : ការសិក្សា និងស្ទាបស្ទង់មតិមិនទាន់ដែលបានធ្វើឡើយ ។

<u>ស្ថាប័នតុលាការដែលមានភារកិច្ចក្នុងអំពើហិង្សាលើកុមារ</u>

***<u>សំណួរទី១៣</u>: ចូរកំណត់អត្តសញ្ញាណរាល់ចនាសម្ព័ន្ធតុលាការដែលមានភារកិច្ចក្នុងអំពើហិង្សាលើកុមារ ។ ចូរបង្ហាញថាតើតុលាការគ្រួសារ ឬតុលាការយុវជនរបស់អ្នក មានការទទួលខុសត្រូវពិសេសទាក់ទងនឹងបញ្ហានេះឬទេ ។***

***ចម្លើយ*** : បច្ចុប្បន្ននេះ រចនាសម្ព័ន្ធតុលាការដែលមានភារកិច្ចក្នុងអំពើហិង្សាលើកុមារ ស្ថិតនៅក្នុងប្រព័ន្ធតុលាការទូទៅ។ នៅកម្ពុជាពុំទាន់មានតុលាការគ្រួសារ ឬ តុលាការយុវជនសម្រាប់ទទួលខុសត្រូវពិសេសដោយឡែកដែលទាក់ទងនឹងបញ្ហានេះទេ។

**អាយុអប្បបរមាសម្រាប់ទំនាក់ទំនងផ្លូវភេទ**

***សំណួរទី១៤:*** ***ចូរផ្តល់ព័ត៌មាន ស្តីពីការកំណត់ដោយច្បាប់នូវអាយុអប្បបរមាសម្រាប់ទំនាក់ទំនងផ្លូវភេទ។ តើអាយុនេះមានភាពខុសគ្នាទេចំពោះបុរស និងស្ត្រី? តើអាយុនេះខុសគ្នាឬទេចំពោះសកម្មភាពផ្លូវភេទនៃភេទដូចគ្នា និងភេទមិនដូចគ្នា?***

***ចម្លើយ*** : សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីមានកំណត់អំពីអាយុអប្បបរមានៃការរួមភេទ ដែលមានសេចក្តីថានីតិភាពនៃការរួមភេទត្រូវបានកំណត់ចាប់ពីអាយុ ១៥ឆ្នាំ។

***សំណួរទី១៥*** : ***ចូរផ្តល់ព័ត៌មានទាក់ទងនឹងអាយុដែលអនុញ្ញាតឱ្យបុរស និងស្ត្រីរៀបអាពាហ៍ពិពាហ៍បាន។***

***ចម្លើយ*** :

- ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ

*មាត្រា៥ : អាចរៀបអាពាហ៍ពិពាហ៍បាន បុរសចាប់ពីអាយុ ២០ឆ្នាំឡើង នារីចាប់ពីអាយុ ១៨ឆ្នាំឡើង។*

*ក្នុងករណីពិសេស បុរសដែលមានអាយុមិនទាន់ដល់ ២០ឆ្នាំ និងនារីដែលមានអាយុមិនទាន់ដល់ ១៨ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍ស្របច្បាប់បាន ប្រសិនបើនារីមានផ្ទៃពោះ ហើយមានការអនុញ្ញាតពីឪពុកម្តាយ ឬអ្នកអាណាព្យាបាល។*

**ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ**

***សំណួរទី១៦*** : ***ចូរផ្តល់ព័ត៌មានលើច្បាប់ ឬវិធានការផ្សេងទៀតដើម្បីទប់ស្កាត់ការជួញដូរ កេងប្រវ័ញ្ចផ្លូវភេទលើកុមារ រាប់ទាំងតាមរយៈការធ្វើពេស្យាចារ និង សកម្មភាពផ្លូវភេទខុសច្បាប់ផ្សេងទៀត។ ចូរផ្តល់ព័ត៌មានលម្អិតថាកុមាររងគ្រោះដោយការកេងប្រវ័ញ្ចមិនត្រូវបានផ្តន្ទាទោសនោះទេ។ ចូរផ្តល់ព័ត៌មានលើច្បាប់ ឬ វិធានការផ្សេងទៀតដែលមិនអនុញ្ញាតឱ្យមានការលក់ ឬការជួញដូរកុមារ រាប់ទាំងដោយឪពុកម្តាយផង។***

***ចម្លើយ*** : ច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្សឆ្នាំ១៩៩៦ មាត្រា៣ មាត្រា៤ មាត្រា៧ និង មាត្រា៨។

ច្បាប់នៅកម្ពុជាមិនបានផ្តន្ទាទោសជនរងគ្រោះដោយអំពើជួញដូរ ឬជាជនពេស្យាចារឡើយ។

បច្ចុប្បន្ននេះ រដ្ឋាភិបាលបានសហការជិតស្និទ្ធិជាមួយអង្គការក្រៅរដ្ឋាភិបាលក្នុងការផ្តល់ទីជម្រក និងសេវាទៅជនរងគ្រោះ។ កម្ពុជាមានផែនការជាតិ៥ឆ្នាំ ប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ២០០០-២០០៤ ដែលក្នុងនោះមានកម្មវិធីធំ៧៤ គឺ : កិច្ចបង្ការទប់ស្កាត់ កិច្ចការពារ ការស្តារនិងអភិវឌ្ឍសមត្ថភាព និង សមាហរណកម្មទៅក្នុងសហគមន៍។

## ***រូបភាពអាសអាភាស និងព័ត៌មានមិនល្អ***

***សំណួរទី១៧*: ចូរផ្តល់ព័ត៌មានលើច្បាប់ ឬវិធានការផ្សេងទៀតដែលហាមឃាត់មិនឱ្យផលិត កាន់កាប់ និងចែកចាយរូបភាពអាសអាភាសរបស់កុមារ ។ ដោយឡែក ចូរផ្តល់ព័ត៌មានលើការត្រួតពិនិត្យរូបភាពអាសអាភាសដែលត្រូវផលិត និង ឬចែកចាយតាមប្រព័ន្ធអ៊ិនធឺណេត ។**

***ចម្លើយ* :**

នៅឆ្នាំ២០០២ កម្ពុជាបានផ្តល់សច្ចាប័នលើពិធីសារជ្រើសរើស ស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ និងពិធីសារស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារនិងការផ្សព្វផ្សាយរូបភាពអាសអាភាសកុមារ ។

រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ស្តីពីការគ្រប់គ្រង់ ត្រួតពិនិត្យសិល្បៈភាពយន្ត និងវីដេអូ មាត្រា២២ មាត្រា២៨ មាត្រា២៩ ។

រាជរដ្ឋាភិបាល បានចេញសេចក្តីសម្រេចលេខ ១០ សសរ ចុះថ្ងៃទី០២ កុម្ភៈ ឆ្នាំ២០០១ ស្តីពី ការបង្កើតគណៈកម្មការអន្តរក្រសួងបង្ក្រាបបទល្មើសភាពយន្ត និងវីដេអូ ក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីត្រួតពិនិត្យ និងចាត់វិធានការបង្ក្រាបការបញ្ចាំងវីដេអូអាសអាភាស ការលក់ ឬជួល ស្នាដៃភាពយន្ត និងស្នាដៃវីដេអូអាសអាភាស គ្មានទិដ្ឋាកាគ្រប់ប្រភេទ ។

***សំណួរទី១៨*: ចូរផ្តល់ព័ត៌មានលើច្បាប់ ឬការណែនាំផ្សេងៗ ដើម្បីការពារកុមារពីព័ត៌មាន និងឧបករណ៍មិនល្អដែលត្រូវបានបញ្ជូនតាមរយៈប្រព័ន្ធផ្សព្វផ្សាយ អ៊ិនធឺណេត វីដេអូហ្គេម ។ល ។**

***ចម្លើយ* :** អនុក្រឹត្យរាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រង និងការត្រួតពិនិត្យភាពយន្ត និងវីដេអូ ចុះថ្ងៃទី០៤ កញ្ញា ២០០០ តម្រូវឱ្យគ្រប់ភាពយន្ត និងវីដេអូទាំងអស់ដែលផលិតនៅក្នុងនិងក្រៅប្រទេស ត្រូវមានអាជ្ញាប័ណ្ណជាមុនសិនមុននឹងធ្វើអាជីវកម្ម ។

ដើម្បីជំរុញឱ្យអនុក្រឹត្យរឹតតែមានប្រសិទ្ធភាព ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានចេញសារាចរណែនាំ ចុះថ្ងៃទី ២០ តុលា ២០០០ បញ្ជាក់ថា ក្រសួងនឹងមិនផ្តល់អាជ្ញាប័ណ្ណឱ្យធ្វើអាជីវកម្មទៅភាពយន្ត វីដេអូ កាសែត Laser Disc, Video CD, DVD…Karaokeណា ដែលមានរូបភាពអាសអាភាស អំពើប្លន់ ការកាប់សម្លាប់ ភាពសាហាវព្រៃផ្សៃ ការជួញដូរគ្រឿងញៀន ការកេងប្រវ័ញ្ចផ្លូវភេទ ការជួញដូរកុមារ និងការចាប់ជំរិត ។

ក្រសួងព័ត៌មានបានចេញសេចក្តីណែនាំលេខ ០០៣៧ ពម.សរ ចុះថ្ងៃទី១៤ មករា ១៩៩៩ ដែលមិនអនុញ្ញាតឱ្យស្ថានីយទូរទស្សន៍បញ្ចាំងឈុតរំលោភ ឈុតអាសអាភាសឡើយ ។ ខ្សែភាពយន្តដែលមានសាច់រឿងមានភាពសាហាវ ការកាប់សម្លាប់ បងធំ ការចាប់ជំរិត ភេរវកម្ម ត្រូវតែបញ្ចាំងក្រោយម៉ោង ៩យប់ទៅ ។ ស្ថានីយទូរទស្សន៍ទាំងអស់មិនត្រូវបញ្ចាំងរាល់ការសំដែងដែលមានបញ្ចូលភាពសាហាវឃោរឃៅ ដែលអាចប៉ះពាល់ដល់កុមារ ហើយមិនត្រូវអនុញ្ញាតឱ្យកុមារចូលសំដែងក្នុងកម្មវិធីណាដែលគ្មានការអប់រំ ដែលអាចបង្កឱ្យមានឥទ្ធិពលអាក្រក់ដល់កុមារដ៏ទៃទៀត ។ រាល់ការផ្សាយពាណិជ្ជកម្មដែលមានលក្ខណៈលើកទឹកចិត្តឱ្យកុមារជក់បារី និងផឹកគ្រឿងស្រវឹងត្រូវបានហាមឃាត់ ។

រាជរដ្ឋាភិបាល បានឯកភាពជាគោលការណ៍លើអនុសាសន៍ ៦ចំណុចនៃកិច្ចប្រជុំអន្តរក្រសួង ដើម្បីបង្ក្រាប និងទប់ស្កាត់ការផ្សព្វផ្សាយរូបភាពអាសអាភាសរបស់ស្ត្រីតាមប្រព័ន្ធអេឡិចត្រូនិច ។ គោលការណ៍ទាំងនោះមានៈ

១- បិទ Block IP ក្នុង Internet ដែលអាចបញ្ជូនរូបភាពអាសអាភាស

២- រៀបចំគណៈកម្មាធិការប្រតិបត្តិយុទ្ធនាការត្រួតពិនិត្យតាមដានការផ្សព្វផ្សាយរូបភាពអាសអាភាសគ្រប់វិធីដោយមានថវិកាសម្រាប់ទ្រទ្រង់សកម្មភាពអប់រំ អង្កេតតាមដាន ត្រួតពិនិត្យ និងបង្ក្រាបឱ្យមានប្រសិទ្ធភាព

៣- ក្រសួងយុត្តិធម៌ ត្រូវពិនិត្យបំពេញបន្ថែមនូវចន្លោះខ្វះខាតនៃសេចក្តីព្រាងច្បាប់ថ្មី ស្តីពីការបង្ក្រាបការជួញដូរមនុស្ស ហើយត្រូវជំរុញការអនុម័តឱ្យបានឆាប់

៤- ក្រសួងកិច្ចការនារី ត្រូវត្រៀមរៀបចំសារាចរណែនាំរបស់រាជរដ្ឋាភិបាល ដើម្បីជួយសម្រួលដល់ការអនុវត្ត ក្នុងដំណាក់កាលរង់ចាំការអនុម័តច្បាប់

៥- ក្រសួងនីមួយៗត្រូវមានវិធានការណែនាំ និងអប់រំមន្ត្រីរាជការកុំឱ្យមើល និងផ្សព្វផ្សាយរូបភាពអាសអាភាស

៦- រៀបចំយុទ្ធនាការអប់រំយុវវ័យ និងសង្គម ដោយសហការជាមួយគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ។

ច្បាប់ស្តីពីរបបសារព័ត៌មាន ចុះថ្ងៃទី១ កញ្ញា ១៩៩៥ មាត្រា១៤ និង ១៥ បានហាមឃាត់សារព័ត៌មានមិនឱ្យបោះពុម្ពផ្សាយនូវអ្វីដែលប៉ះពាល់ដល់ប្រពៃណីល្អរបស់សង្គមជាតិ ហើយដំណឹង រូបថត ឬគំនូរ ដែលអាចឱ្យអ្នកអានស្គាល់ឈ្មោះនិងភិនភាគរបស់ភាគីក្នុងរឿងរដ្ឋប្បវេណី ដែលទាក់ទងទៅនឹងបិតុភាព អាពាហ៍ពិពាហ៍ រឿងលែងលះប្តីប្រពន្ធ ឬរឿងអាណាព្យាបាលលើកុមារ យុវជនអាយុតិចជាងដប់ប្រាំបីឆ្នាំ ស្ត្រីដែលរងគ្រោះដោយអំពើរំលោភលើរាងកាយ ឬ អំពើចាប់បង្ខំសេពសន្ថវៈ ។ បុគ្គលណាដែលត្រូវសារព័ត៌មានបំពានសិទ្ធិខាងលើនេះ មានសិទ្ធិប្តឹងទៅតុលាការដើម្បីទាមទារជម្ងឺចិត្តបាន ។

**<u>កាតព្វកិច្ចរាយការណ៍ទាក់ទងនឹងអំពើហិង្សាលើកុមារ</u>**

***<u>សំណួរទី១៩</u> : ផ្តល់ព័ត៌មានស្តីពីច្បាប់ បទបញ្ជា ឬការណែនាំរដ្ឋបាលដែលតម្រូវឱ្យរាយការណ៍អំពីរាល់ទម្រង់នៃអំពើហិង្សា និងការរំលោភលើកុមារនៅក្នុងគ្រប់ករណីទៅអាជ្ញាធរមានសមត្ថកិច្ច ។ បើសិនជាមានច្បាប់ បទបញ្ជា ឬការណែនាំរដ្ឋបាលដែលតម្រូវឱ្យរាយការណ៍ តើពលរដ្ឋទាំងអស់មានកាតព្វកិច្ចរាយការណ៍ ឬក៏កាតព្វកិច្ចរាយការណ៍នោះធ្លាក់ទៅលើក្រុមជំនាញណាមួយប៉ុណ្ណោះ? ចូរផ្តល់ព័ត៌មានលម្អិតលើទណ្ឌកម្មនៃការមិនរាយការណ៍ ។***

**<u>ចម្លើយ</u> :**

- អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន ចុះថ្ងៃទី២៩ ធ្នូ ២០០០ មាត្រា ៣៦
- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ១៩៨៩ មាត្រា១១៩ និងមាត្រា១២០

ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ អនុញ្ញាតឱ្យតុលាការចេញដីកាការពារ ក្នុងគោលបំណងការពារជនរងគ្រោះពីអំពើហិង្សា។ ពាក្យបណ្តឹងសុំដីកានេះ អាចធ្វើឡើងដោយជនណាម្នាក់ដែលដឹងពីឧប្បត្តិហេតុនៃអំពើហិង្សាក្នុងគ្រួសារ ប្រសិនជនរងគ្រោះជាកុមារ ជនវិកលចរិត ឬជាជនដែលតុលាការយល់ថាគ្មានលទ្ធភាពធ្វើពាក្យ បណ្តឹងដោយខ្លួនឯង

បាន។ នេះមិនមែនជាកាតព្វកិច្ចទេ តែជាលទ្ធភាពផ្តល់ឱ្យអ្នកដែលដឹងពីអំពើហិង្សាក្នុងគ្រួសារដើម្បីសុំដីកាការពារជនរងគ្រោះពីតុលាការ។ ប្រជាពលរដ្ឋ ក្រុមជំនាញ ឬអង្គការនានាមានសិទ្ធិធ្វើការរាយការណ៍ពីបទល្មើសជាក់ស្តែងទៅសមត្ថកិច្ច។ ច្បាប់នៅកម្ពុជាមិនបានកំណត់ឱ្យមានការ ផ្តន្ទាទោសដល់អ្នកដែលមិនរាយការណ៍ទេ។ ច្បាប់មិនតម្រូវឱ្យប្រជាពលរដ្ឋទូទៅ ឬក្រុមជំនាញរាយការណ៍ឡើយ លើកលែងតែក្នុងករណីដូចមានចែងក្នុងអនុក្រឹត្យលេខ ១០៣ ខាងលើ។

**<u>នីតិវិធីបណ្តឹង</u>**

***<u>សំណួរទី២០</u> : ចូរផ្តល់ព័ត៌មានស្តីពីនីតិវិធីបណ្តឹងទាក់ទងទៅនឹងរាល់ទម្រង់នៃអំពើហិង្សាលើកុមារ ដែលប្រព្រឹត្តទៅនៅ :***

- ***ក្នុងគ្រួសារ ឬផ្ទះ***
- ***ក្នុងសាលារៀន និងការថែទាំ ការអប់រំមិននៅក្នុងសាលា (ទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ទាំងរដ្ឋនិងឯកជន)***
- ***សាលាយោធា***
- ***មជ្ឈមណ្ឌលអប់រំ រាប់ទាំងកន្លែងថែទាំ សុខភាព និងសុខភាពផ្លូវចិត្ត***
- ***ការអនុវត្តច្បាប់ និងសណ្តាប់ធ្នាប់សាធារណៈ រាប់ទាំងកន្លែងឃុំខ្លួនបណ្តោះអាសន្ន ឬមន្ទីរឃុំឃាំង***
- ***កន្លែងអ្នកជិតខាងគ្នា នៅតាមផ្លូវ និងសហគមន៍ រាប់ទាំងទីជនបទ***
- ***កន្លែងធ្វើការ (ផ្លូវការ ឬមិនផ្លូវការ)***
- ***ពេលធ្វើកីឡា និងកន្លែងលេងកីឡា***

***<u>ចម្លើយ</u>*** : មិនមាននីតិវិធីពិសេសណាសម្រាប់អនុវត្តទៅលើគ្រប់ទម្រង់នៃអំពើហិង្សាលើកុមារទេ។ សូម្បីតែច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះមិនមានចែងពីនីតិវិធីដោយឡែកដែរ។ នីតិវិធីបណ្តឹងទាក់ទងទៅនឹងរាល់ទម្រង់នៃអំពើហិង្សាលើកុមារនៅគ្រប់ទីកន្លែងត្រូវដំណើរការតាមនីតិវិធីព្រហ្មទណ្ឌ១៩៩៣ គឺអ្នកតំណាងស្របច្បាប់(ឪពុកម្តាយ ឬជនដែលច្បាប់ចាត់តាំង)អាចដាក់ពាក្យបណ្តឹងទៅមន្ត្រីនគរបាលយុត្តិធម៌ (ព្រះរាជអាជ្ញា ឬ នគរបាលប៉ុស្តិ៍រដ្ឋបាល។ល។) ដែលនឹងធ្វើការស៊ើបអង្កេត (មាត្រា៣៨)។ របាយការណ៍ ស្តីពីការស៊ើបអង្កេតនឹងត្រូវបញ្ជូនទៅព្រះរាជអាជ្ញាដែលជាអ្នកធ្វើបណ្តឹងអាជ្ញាប្រឆាំងនឹងជនល្មើស។ ក្នុងរឿងរដ្ឋប្បវេណីមួយចំនួនដែលប៉ះពាល់ សណ្តាប់ធ្នាប់សាធារណៈ ឬដល់ប្រយោជន៍អនីតិជន ឬអសមត្ថជន។ល។ តំណាងអយ្យការត្រូវតាំងខ្លួនជាគូក្តីដើម។ ក្នុងករណីនេះអយ្យការចាត់ការដោយឯកឯង។

***<u>សំណួរទី ២១</u> : ចូរបង្ហាញថា តើកុមារ ឬ អ្នកដែលតំណាងកុមារអាចចូលពិនិត្យនីតិវិធីបានដែរឬទេ។ ចូរបង្ហាញថា តើមានជំនួយផ្នែកច្បាប់សម្រាប់សម្រួលការដាក់ពាក្យបណ្តឹង និងបង្ហាញពីកាលៈទេសៈ ដែលអាចឱ្យទទួលបានជំនួយនោះ ។***

***<u>ចម្លើយ</u>*** : រាល់សំណុំរឿង កុមារ ឬ តំណាងកុមារ ឬ មេធាវីអ្នកការពារសិទ្ធិឱ្យកុមារ និងអ្នកដើមបណ្តឹងអាចចូល

ពិនិត្យនីតិវិធីបានគ្រប់ពេល ។

ជាទូទៅ មានអង្គការក្រៅរដ្ឋាភិបាលជាច្រើនដែលផ្តល់ជំនួយផ្នែកច្បាប់ដល់ជនរងគ្រោះដែលក្នុងនោះមានអនីតិ-ជនផងដែរ ហើយនិងជួយសម្រួលការដាក់ពាក្យប្តឹង ។

លើសពីនេះទៅទៀត អង្គការយូនីសេហ្វនៅកម្ពុជាបានផ្តល់ជំនួយផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុទៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាតាំងពីឆ្នាំ២០០០ ។ តាមរយៈជំនួយនេះ អង្គភាពតំណាងផ្នែកច្បាប់សម្រាប់កុមារដែលត្រូវការកិច្ចការពារពិសេសត្រូវបានបង្កើតឡើង ហើយដែលមានមេធាវីចំនួន ៣រូបជាសមាជិកដើម្បីផ្តល់ជំនួយដោយមិនគិតថ្លៃចំពោះកុមាររងគ្រោះ ។ ការទទួលបាននូវជំនួយផ្នែកច្បាប់អាចត្រូវបានផ្តល់ចំពោះគ្រួសារក្រីក្រ ឬករណីដែលមានការរំលោភបំពានពីអ្នកអាណាព្យាបាល ។

***<u>សំណួរទី ២២</u> : ចូររៀបរាប់ពីជំហានដែលបានធ្វើដើម្បីលើកកម្ពស់ការយល់ដឹងស្តីពីលទ្ធភាពនៃការដាក់ពាក្យបណ្តឹងទាក់ទងនឹងអំពើហិង្សាលើកុមារ ។***

***<u>ចម្លើយ</u>*** : តាំងពីឆ្នាំ១៩៩៩មក ដោយមានការជួយគាំទ្រពីអង្គការយូនីសេហ្វ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បានអនុវត្តគម្រោងការសាកល្បង "**បណ្តាញការពារកុមារនៅតាមសហគមន៍** " នៅប្រាំខេត្ត ក្រុង ក្នុងគោលបំណងទប់ស្កាត់អំពើហិង្សា ការកេងប្រវ័ញ្ច និងការជួញដូរកុមារ ហើយជំរុញឱ្យមានការកំណត់មុខ សញ្ញាកុមាររងគ្រោះ និងផ្តល់សេវាសមស្រប ។ បច្ចុប្បន្នគម្រោងការនេះ ដោយមានការបន្ថយជំនួយពីអង្គការយូនីសេហ្វ ត្រូវបានរៀបចំសម្រួលឡើងវិញ ដោយអនុវត្ត នៅតែក្នុងខេត្តព្រៃវែង និង ស្វាយរៀងប៉ុណ្ណោះ ។ តាមរយៈក្រសួង ស្ថាប័នខេត្តក្រុង ឃុំ ភូមិ សកម្មជន អង្គការស្ម័គ្រចិត្ត និងអង្គការមិនមែនរដ្ឋាភិបាល ធ្វើសកម្មភាពរៀងរាល់ថ្ងៃដើម្បីណែនាំប្រជាពលរដ្ឋខ្មែរ ព្រមទាំងផ្តល់នូវលទ្ធភាពនៃការការដាក់ពាក្យបណ្តឹងនេះ ។

***<u>សំណួរទី ២៣</u> : ចូរផ្តល់ព័ត៌មាន ស្តីពីនីតិវិធីពិសេស ឬ វិធាននៃការបង្ហាញភស្តុតាង ដែលអាចអនុវត្តបានទៅលើរឿងក្តីទាក់ទងនឹងអំពើហិង្សាលើកុមារ ។***

***<u>ចម្លើយ</u>*** : ទោះបីនៅកម្ពុជាពុំទាន់មាន បទប្បញ្ញត្តិពិសេសទាក់ទងនឹងការបង្ហាញភស្តុតាង លើអំពើហិង្សាលើកុមារក៏ដោយ ក៏ប៉ុន្តែ ការបង្ហាញភស្តុតាងក្នុងដំណើរក្តីព្រហ្មទណ្ឌ ដែលមានទាំងរឿងក្តីអំពើហិង្សាលើកុមារផងបានកំណត់នៅ ក្នុងច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ( មាត្រា២) ។

***<u>សំណួរទី ២៤</u> : ចូរផ្តល់ព័ត៌មាន ស្តីពីលទ្ធផលជាទូទៅនៃបណ្តឹងទាក់ទងនឹងអំពើហិង្សាលើកុមារ (ឧ. សំណងការដាក់ទណ្ឌកម្មលើជនល្មើស ការស្តារនីតិសម្បទាជនល្មើស ការអប់រំគ្រួសារ) ។***

***<u>ចម្លើយ</u>*** : នៅប្រទេសកម្ពុជាបណ្តឹងទាក់ទងនឹងអំពើហឹង្សាលើកុមារ ក៏ដូចជាបណ្តឹងនៃអំពើល្មើសព្រហ្មទណ្ឌនានាដែរ គឺតំណាងអយ្យការជាម្ចាស់នៃបណ្តឹងអាជ្ញា ប្តឹងចោទប្រកាន់ជនប្រព្រឹត្តល្មើសទៅតុលាការព្រហ្មទណ្ឌដើម្បីផ្តន្ទាទោសតាមច្បាប់ ។ ចំណែកជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់ពាក្យបណ្តឹងទាមទារសំណង រួមជាមួយ

នឹងបណ្ដឹងអាជ្ញារបស់តំណាងអយ្យការបាន។ តុលាការព្រហ្មទណ្ឌ នៃរឿងក្ដីនេះអាចសម្រេចអំពីសំណងនេះ រួមជាមួយនឹងការផ្ដន្ទាទោស។

ការស្ដារនីតិសម្បទាជនល្មើស និងការអប់រំគ្រួសារ មានឆ្លើយទៅនឹងសំណួរទី២៥ខាងក្រោម។

***<u>សំណួរទី ២៥</u> : ចូរផ្ដល់ព័ត៌មាន ស្ដីពីលទ្ធផលជាទូទៅនូវដំណើរការក្ដីដែលក្នុងនោះកុមារ និងយុវជន ត្រូវបានរកឃើញថាមានកំហុសក្នុងការប្រព្រឹត្តអំពើហិង្សា (ឧ. ការដាក់ពន្ធនាគារ ការដាក់ទណ្ឌកម្មលើរូបរាងកាយ ធ្វើការឱ្យសហគមន៍ ការស្ដារនីតិសម្បទាជនល្មើស ការអប់រំគ្រួសារ)។***

***<u>ចម្លើយ</u>*** : អំពីលទ្ធផលជាទូទៅ នៃការដំណើររឿងក្ដីកុមារ ឬយុវជនដែលប្រព្រឹត្តអំពើហិង្សា យើងបានបែងចែកជា២ផ្នែក :

ទី១: កុមារដែលមានអាយុក្រោម ១២ ឆ្នាំ ត្រូវបានធ្វើការអប់រំ និងបញ្ជូនទៅទៅមជ្ឈមណ្ឌលយុវនីតិសម្បទា ដើម្បីអប់រំ ទន្ទឹមនេះក៏មានលើកកម្ពស់ការអប់រំឳពុកម្ដាយជាប្រចាំ ដើម្បីបង្កើនការអប់រំកូនរបស់ខ្លួន មុននឹងធ្វើសមាហរណកម្មទៅក្នុងសហគមន៍វិញ។

ទី២: ចំពោះយុវជន ដែលមានអាយុក្រោម ១៨ ឆ្នាំ យើងបានធ្វើការអប់រំ ក្នុងករណីដែលមានទោសជាលក្ខណៈឧក្រិដ្ឋ យើងនឹងបញ្ជូនទៅដោះស្រាយតាមប្រព័ន្ធតុលាការ ដែលកាត់ទោសពាក់កណ្ដាលមនុស្សចាស់។

## II. ក្របខ័ណ្ឌការងារតាមគ្រឹះស្ថាន និងធនធានទាំងឡាយ ដើម្បីដោះស្រាយអំពើហិង្សាលើកុមារ

***<u>សំណួរទី ២៦</u> : តើមានអាជ្ញាធររដ្ឋាភិបាល រចនាសម្ព័ន្ធ និងយន្ដការ រាប់ទាំងថ្នាក់រដ្ឋសហព័ន្ធ ថ្នាក់រដ្ឋ ឬ ខេត្ត-ក្រុង និងតំបន់ដែលទទួលខុសត្រូវក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើកុមារ ?***

***បើសិនជាមាន ចូរកំណត់អត្តសញ្ញាណអាជ្ញាធរទាំងនោះ រចនាសម្ព័ន្ធ និងយន្ដការក្នុងការសម្របសម្រួលការងារ។***

***<u>ចម្លើយ</u>*** : អាជ្ញាធររដ្ឋាភិបាលដែលទទួលខុសត្រូវក្នុងការឆ្លើយតបទៅនឹងអំពើហឹង្សាលើកុមារ គឺស្ថិតនៅក្នុងយន្តការរួមដែលឆ្លើយតបទៅនឹងអំពើល្មើសទូទៅ គឺនគរបាល នគរបាលយុត្តិធម៌ ក្រុមប្រឹក្សាឃុំ សង្កាត់ សហគមន៍ និងក្រសួង សមត្ថកិច្ចពាក់ព័ន្ធ។ យន្តការនេះមានរចនាសម្ព័ន្ធនៅថ្នាក់ក្រសួង ថ្នាក់ខេត្ត-ក្រុង ថ្នាក់ស្រុក-ខ័ណ្ឌ និងថ្នាក់ឃុំ-សង្កាត់ ភូមិ។

កិច្ចការទាំងឡាយត្រូវបានសម្របសម្រួល និងដោះស្រាយតាមយន្តការថ្នាក់និមួយៗពីក្រោមទៅលើ ក្នុងករណីដោះស្រាយបញ្ហាមិនបាន ត្រូវបញ្ជូនករណីនោះមកយន្តការថ្នាក់លើបន្តបន្ទាប់។ ជាចុងក្រោយបំផុត បើទំនាស់មិនអាចដោះស្រាយបានគឺត្រូវបញ្ជូនទៅតុលាការ។

***<u>សំណួរទី ២៧</u> : តើមានអាជ្ញាធររបស់រដ្ឋាភិបាលពិសេស ដែលមានភារកិច្ចទទួលខុសត្រូវដោះស្រាយអំពើហិង្សាលើកុមារដែរឬទេ? បើសិនជាមាន ចូរផ្ដល់ព័ត៌មានលម្អិត***

***ចម្លើយ*** : នៅប្រទេសកម្ពុជាក៏មានអាជ្ញាធរពិសេស ដែលមានភារកិច្ចទទួលខុសត្រូវដោះស្រាយអំពើហិង្សាលើកុមារដូចជា គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃក្រសួងមហាផ្ទៃ ដែលមានរចនាសម្ព័ន្ធពីថ្នាក់ក្រសួង និងថ្នាក់ខេត្ត-ក្រុង និងសមត្ថកិច្ចដែលមានចែងនៅក្នុងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការពារជនរងគ្រោះត្រង់ជំពូក៣ មាត្រា៩-១០-១១-១២។

***សំណួរទី ២៨*** : ***តើធនធានពិសេសផ្នែកហិរញ្ញវត្ថុ និង ឬមនុស្ស ត្រូវបានផ្តល់ដោយប្រទេសអ្នក ក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាទូទៅឬទេ? បើសិនជាមាន ចូរបង្ហាញពីវិសាលភាពធនធានទាំងនេះ ។***

***ចម្លើយ*** : ក្រសួងដែលធ្វើការងារកុមារជាអាទិ៍មាន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងកិច្ចការនារី ក្រសួងទេសចរណ៍ ក៏មានធ្វើការងារប្រឆាំងអំពើហិង្សាផងដែរ ដោយប្រើប្រាស់ថវិការបស់រដ្ឋ និងជំនួយពីអង្គការនានា ។

***សំណួរទី ២៩*** : ***តើប្រទេសអ្នកបានផ្តល់ធនធានពិសេសផ្នែកហិរញ្ញវត្ថុ និង ឬមនុស្ស ដើម្បីឆ្លើយតបនឹងអំពើហិង្សាលើកុមារដែរឬទេ? បើសិនជាមាន ចូរផ្តល់ព័ត៌មានលម្អិត ។***

***ចម្លើយ*** : រាជរដ្ឋាភិបាលបានផ្តល់មូលនិធិគិតជាតម្លៃផ្នែកបដិភាគជាដី ឬទីតាំងសាងសង់យ៉ាងច្រើនសម្រាប់កសាងភូមិកុមារ និងកម្មវិធីកុមារទៅក្រសួង ស.អ.យ និងបានផ្តល់ថវិកា មន្រ្តីដល់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្រ្តី ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។ ទោះជាការប្រឆាំងអំពើហិង្សាលើកុមារនៅមានកម្រិត ប៉ុន្តែក៏បានរួមចំណែកដោយប្រយោល និងដោយផ្ទាល់ផ្នែកធនធានមនុស្សតាមលទ្ធភាពដែលមានដើម្បីទប់ស្កាត់អំពើហិង្សាលើកុមារ និងកិច្ចការពារកុមារផងដែរ ។

***សំណួរទី ៣០*** : ***តើម្ចាស់ជំនួយអន្តរជាតិ ឬ ទ្វេភាគីបានផ្តល់ធនធានទៅប្រទេសអ្នកសម្រាប់សកម្មភាពឆ្លើយតបនឹងអំពើហិង្សាលើកុមារដែរឬទេ? បើសិនជាមាន ចូរបង្ហាញពីវិសាលភាពនៃធនធាននោះ និងរបៀបប្រើប្រាស់។***

***ចម្លើយ*** : បន្ថែមពីលើធនធានរបស់រដ្ឋ ធនធានរបស់អន្តរជាតិ ឬទ្វេភាគីបានត្រូវផ្តល់ដល់ក្រសួងជំនាញដែលពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាលដែលអនុវត្តកម្មវិធីប្រឆាំងអំពើហិង្សាក្នុងគ្រួសារដែលភាគច្រើនប្រមូលផ្តុំទៅលើទិដ្ឋភាពនៃការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទ ការពង្រឹង ការអនុវត្តច្បាប់ ការថែទាំជំនួសចំពោះកុមារកំព្រា និងកុមារដែលងាយរងគ្រោះ។ ក្រៅពីនេះ ជំនួយអន្តរជាតិ ឬទ្វេភាគី ក៏បានផ្តល់ដល់កម្មវិធីផ្សេងៗទៀតដូចជាៈ កម្មវិធីប្រឆាំងអំពើហិង្សាក្នុងគ្រួសារ ការបណ្តុះបណ្តាលមន្រ្តី ការពិគ្រោះផ្តល់យោបល់ ការលើកកម្ពស់ការយល់ដឹង ការអប់រំ ផ្សព្វផ្សាយ វេទិកាតស៊ូមតិ។ល។ ប៉ុន្តែទោះជាយ៉ាងនេះក្តី កម្ពុជាត្រូវការបន្ថែមទៀតនូវជំនួយថវិកាដើម្បីអភិវឌ្ឍកម្មវិធីតាមវិស័យផ្សេងៗទៀត និងតាមតម្រូវការចាំបាច់ឱ្យមានប្រសិទ្ធភាព ។

***សំណួរទី ៣១*** : ***តើប្រទេសអ្នកបានផ្តល់ជំនួយទៅប្រទេសផ្សេងទៀត ក្នុងកិច្ចប្រឹងប្រែងឆ្លើយតបនឹងបញ្ហាអំពើហិង្សាលើកុមារដែរឬទេ? បើសិនជាមាន ចូរផ្តល់ព័ត៌មានលម្អិត ។***

***ចម្លើយ*** : ប្រទេសកម្ពុជាពុំបានផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុទៅប្រទេសផ្សេងៗលើការងារអំពើហិង្សាលើកុមារទេ ប៉ុន្តែរាជរដ្ឋាភិបាលបានផ្តល់នូវការគាំទ្រ និងកិច្ចសហប្រតិបត្តិការជាបន្តបន្ទាប់ជាមួយប្រទេសជិតខាងដូចជា ករណីបញ្ជូនកុមាររងគ្រោះទៅប្រទេសវៀតណាម និងការទទួលកុមារពីប្រទេសថៃក្រោមការឧបត្ថម្ភពីអង្គការយូនីសេហ្វ IOM និងកិច្ចសហការជាមួយរាជរដ្ឋាភិបាលថៃជាដើម។ ទន្ទឹមនឹងនេះរាជរដ្ឋាភិបាលកម្ពុជាក៏បានបញ្ជូនមន្ត្រីជំនាញទៅចូលរួមចែករំលែក ដកពិសោធន៍ លើទម្រង់អំពើហិង្សាក្នុងគ្រួសារក្នុងកិច្ចប្រជុំប្រចាំតំបន់ និងអន្តរជាតិជាបន្តបន្ទាប់។

***សំណួរទី ៣២*** ***: បើសិនជាប្រទេសអ្នកមានវិទ្យាស្ថានជាតិសិទ្ធិមនុស្ស ដូចជាគណៈកម្មាការសិទ្ធិមនុស្ស ឬ កន្លែងសម្រុះសម្រួល ឬ វិទ្យាស្ថានជាតិសិទ្ធិកុមារ តើមានតួនាទី ឬ សមត្ថកិច្ចទៅលើអំពើហិង្សាលើកុមារដែរឬទេ? រាប់ទាំងការទទួលពាក្យបណ្តឹង? បើសិនជាមាន ចូរផ្តល់ព័ត៌មានលម្អិត។***

***ចម្លើយ*** : រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាមួយនៅថ្ងៃទី ១៩ ខែមករា ឆ្នាំ២០០០។ គណៈកម្មាធិការនេះមានតួនាទីជួយរាជរដ្ឋាភិបាលក្នុងការងារ :

- ការពារលើកស្ទួយអភិវឌ្ឍន៍សិទ្ធិមនុស្សលទ្ធិប្រជាធិបតេយ្យ ត្រួតពិនិត្យរាល់ការរំលោភសិទ្ធិមនុស្ស និងទទួលពាក្យបណ្តឹងតវ៉ានានា។
- ស្រាវជ្រាវអង្កេតករណីនានា ឬធ្វើការវាយតម្លៃការស្រាវជ្រាវអង្កេតរបស់សមត្ថកិច្ច ហើយធ្វើសំណុំឯកសារផ្សព្វផ្សាយជូនសាធារណជន ជូននាយករដ្ឋមន្ត្រី និងជូនតុលាការ។
- អប់រំផ្សព្វផ្សាយអំពីសិទ្ធិមនុស្សជាសាធារណៈ
- ផ្តល់យោបល់ និងលើកសំណើជូនរាជរដ្ឋាភិបាលអំពីសភាពការណ៍សិទ្ធិមនុស្ស សំដៅធ្វើការកែលំអ និងធ្វើយ៉ាងណាឱ្យកាន់តែសមស្របនឹងរដ្ឋធម្មនុញ្ញ ច្បាប់ប្រទេស និងអនុសញ្ញាទាំងឡាយរបស់អន្តរជាតិ។
- គាំទ្រសហការជាមួយអង្គការសង្គមស៊ីវិល ដើម្បីបុព្វហេតុការពារ និងអភិវឌ្ឍន៍វិស័យសិទ្ធិមនុស្សនៅកម្ពុជា។

***សំណួរទី ៣៣*** ***: តើមានរចនាសម្ព័ន្ធសភា (ឧ. គណៈកម្មាធិការពិសេស) ដើម្បីឆ្លើយតបនឹងអំពើហិង្សាលើកុមារដែរឬទេ? បើសិនជាមាន ចូរផ្តល់ព័ត៌មានលម្អិត។***

***ចម្លើយ*** : រដ្ឋសភា និងព្រឹទ្ធសភានៅកម្ពុជា សុទ្ធតែមានគណៈកម្មការសិទ្ធិមនុស្ស និងទទួលពាក្យបណ្តឹងដែលមានសមត្ថកិច្ចទទួលពាក្យបណ្តឹង និងចុះពិនិត្យលើរាល់ការរំលោភសិទ្ធិមនុស្សគ្រប់ប្រភេទរាប់ទាំងសិទ្ធិកុមារផង។ គណៈកម្មការនេះមិនមានផ្តល់ដំណោះស្រាយលើពាក្យបណ្តឹងនោះទេ តែអាចបញ្ជូនពាក្យបណ្តឹងទៅឱ្យអាជ្ញាធរមានសមត្ថកិច្ចក្នុងការដោះស្រាយ។

***សំណួរទី ៣៤*** ***: តើថ្មីៗនេះសភាប្រទេសអ្នក ធ្លាប់មានគំនិតផ្តួចផ្តើមគួរឱ្យកត់សំគាល់ណាមួយ ទាក់ទងនឹងអំពើហិង្សាលើកុមារដែរឬទេ? បើមាន ចូរផ្តល់ព័ត៌មានលម្អិត។***

***ចម្លើយ*** : រដ្ឋសភា និងព្រឹទ្ធសភាបានអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ នៅឆ្នាំ២០០៥ និងផ្តល់សច្ចាប័នលើអនុសញ្ញាលេខ១៨២របស់អង្គការពលកម្មអន្តរជាតិ (ILO)ស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។ ទន្ទឹមនេះគណៈកម្មាធិការសុខាភិបាល សង្គមកិច្ចអតីតយុទ្ធជន

និងយុវនីតិសម្បទា ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារីនៃរដ្ឋសភា បានដាក់ស្នើសេចក្តីព្រាងដំណោះស្រាយស្តីពីការទប់ស្កាត់ និងការលុបបំបាត់រាល់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ទៅក្នុងមហាសន្និបាតនៃ អង្គការ អន្តរសភាអាស៊ាន (AIPO) លើកទី២៥ ដែលប្រារព្ធធ្វើឡើងនៅទីក្រុងភ្នំពេញ ថ្ងៃទី១២-១៧ កញ្ញា ២០០៤ ហើយត្រូវបានមហាសន្និបាតអនុម័តជាឯកសារសំរាប់ថ្នាក់អាស៊ាន ។

## III. តួនាទីរបស់សង្គមស៊ីវិលនៅក្នុងការដោះស្រាយអំពើហិង្សាលើកុមារ

***<u>សំណួរទី ៣៥</u> : ចូរពិពណ៌នាពីគំនិតផ្តួចផ្តើមពិសេសណាមួយរបស់សង្គមស៊ីវិល ក្នុងការទប់ស្កាត់នឹងអំពើហិង្សាលើកុមារនៅក្នុងប្រទេសអ្នក រាប់ទាំងប្រភេទវិទ្យាស្ថាន (ដូចជា វិទ្យាស្ថានបណ្ឌិតសភា សមាគមវិជ្ជាជីវៈ សមាគមស្ត្រី សមាគមនិស្សិត ក្រុមនៅតាមសហគមន៍ ក្រុមធ្វើមនុស្សធម៌ ក្រុមកុមារនិងយុវជន សហជីពពាណិជ្ជកម្ម អង្គការនិយោជក អង្គការជាតិមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិមិនមែនរដ្ឋាភិបាល) និងសកម្មភាពសំខាន់ៗ (ដូចជាការតស៊ូមតិ ការលើកកម្ពស់ចំណេះដឹង ការស្រាវជ្រាវ ការការពារ ការស្តារនីតិសម្បទា និងការព្យាបាលកុមាររងគ្រោះដោយអំពើហិង្សា ការផ្តត់ផ្គង់សេវា និងការផ្តត់ផ្គង់ធនធាន ។***

**<u>ចម្លើយ</u> :** នៅកម្ពុជាពុំទាន់មានគំនិតផ្តួចផ្តើមពិសេសក្នុងការទប់ស្កាត់អំពើហិង្សាលើកុមារដោយខ្លួនឯងនោះទេ ប៉ុន្តែកន្លងមក សង្គមស៊ីវិលទាំងនោះបានរៀបចំអោយមានសកម្មភាពមួយចំនួនតាមទម្រង់ផ្សេងៗដែលមានដូចខាងក្រោម :

- **ការទាក់ទាញមតិគាំទ្រ ការបង្កាទប់ស្កាត់ និងការលើកកម្ពស់ការយល់ដឹងៈ**

នៅក្នុងការទាក់ទាញមតិគាំទ្រ អង្គការជាច្រើនបានផ្តោតទៅលើការជួញដូរនិងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ។ បណ្តាអ្នកដើរតួសំខាន់ៗនៅក្នុងបញ្ហានេះមាន អង្គការកូសេកាំ អង្គការអ៊ិកផាត អង្គការពលកម្មអន្តរជាតិផ្នែកពលកម្មកុមារ អង្គការអន្តរជាតិទេសន្តរប្រវេសន៍(IOM) អង្គការយូនីសេហ្វ អង្គការទស្សនៈពិភពលោក គណៈកម្មាធិការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ និងក្រុមសុខុមាលភាពកុមារ ។ សកម្មភាពដែលបានធ្វើមានៈ

- ការចូលរួមរៀបចំច្បាប់ ការបណ្តុះបណ្តាល កិច្ចការពារ ការទប់ស្កាត់ និងការផ្តល់សេវាសង្គមដ៏សមស្រប ។
- ផ្តល់ការគាំទ្រដល់បណ្តាញនៅតាមសហគមន៍ដែលដើរតួជាអ្នកចាំឃ្លាំមើលដើម្បីបង្ការទប់ស្កាត់អំពើហិង្សានៅតាមផ្ទះ ការជួញដូរ និងអាជីវកម្មផ្លូវភេទលើកុមារ ។
- ការចូលរួមរបស់កុមារក្នុងការសរសេរព្រឹត្តិប័ត្រ ការនិយាយជាសាធារណៈជាដើម ។

ពាក់ព័ន្ធនឹងអំពើហិង្សាមាន :

- ការផលិតសម្ភារៈផ្សព្វផ្សាយ (ខិត្តប័ណ្ណ Spote ប្រតិទិន)
- ការឱ្យកុមារចូលរួម ប្រឡងគូរគំនូរក្រោមប្រធានបទប្រឆាំងអំពើហិង្សាលើកុមារ

- ការសិក្សាស្រាវជ្រាវរបស់អង្គការធាហ៊្វុនលើកុមារដែល មានអាយុពី១២ ដល់ ១៥ឆ្នាំ ដែលបង្ហាញឱ្យឃើញអំពីប្រេវ៉ាឡង់ និងទស្សនៈរបស់កុមារលើបញ្ហានេះ។ ការសិក្សានេះ បានត្រូវគេយកមកប្រើប្រាស់ជាឧបករណ៍មួយសម្រាប់ទាក់ទាញមតិគាំទ្រឱ្យដើម្បីឆ្លើយតបទៅនឹងអំពើហិង្សាលើកុមារ។

ក្នុងគោលបំណងប្រមូលផ្តុំនូវប្រពៃណីអនុវត្តល្អនៃការចិញ្ចឹមអប់រំកុមារ ចំណេះដឹង និងការយល់ដឹងរបស់ប្រជាជនអំពីបញ្ហាការធ្វើទណ្ឌកម្មលើរាងកាយ និងស្មារតីទៅលើកុមារនៅតាមផ្ទះ នៅពេលថ្មីៗ អង្គការសង្គ្រោះកុមារ Norway បានធ្វើការសិក្សាស្រាវជ្រាវអំពីបញ្ហានេះនៅភ្នំពេញ ស្វាយរៀង ប៉ៃលិន ឧត្តរមានជ័យ។

- **កិច្ចការពារ ការស្តារនីតិសម្បទា និងសមាហរណកម្ម:**

*<u>កិច្ចការពារផ្នែកច្បាប់</u>*

អង្គការមួយចំនួនដូចជា អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ អង្គការសម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស (លីកាដូ) សមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍនៅកម្ពុជា(អាដហុក) អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា(LAC) អង្គការការពារយុត្តិធម៌កុមារ(PJJ) គណៈមេធាវី អង្គការគម្រោងអ្នកការពារក្តីកម្ពុជា(CDP) អង្គការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ(PADV) និងអង្គការផ្សេងៗទៀត បានផ្តល់សេវាកម្មផ្នែកច្បាប់ កិច្ចអន្តរាគមន៍ ការស៊ើបអង្កេត ការពិគ្រោះយោបល់ ការជួយផ្តល់មេធាវី និងជួយរកជម្រកបណ្តោះអាសន្នឱ្យជនរងគ្រោះ និងជនល្មើសជាកុមារ។

*<u>ការស្តារនីតិសម្បទា និងសមាហរណកម្ម</u>*

អង្គការអាហ្វេស៊ីប អង្គការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ អង្គការហាការ មជ្ឈមណ្ឌលថែទាំសុខភាពកុមារ កុមាររីករាយ មាតុភូមិកុមារ ផ្ទះទឹកដូង អង្គការគ្រួសារថ្មី អង្គការទស្សនៈពិភពលោក មជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ(CCPCR) អង្គការគាំពារកុមារដែលងាយរងគ្រោះ(VCAO) បានផ្តល់សេវាស្នាក់នៅ ថែទាំសុខភាពដល់ជនរងគ្រោះ ដើម្បីស្តារនីតិសម្បទា ការពិគ្រោះយោបល់ ផ្តល់កិច្ចការពារឱ្យមានសុវត្ថិភាព ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងធ្វើសមាហរណកម្មទៅក្នុងសហគមន៍វិញ។

អង្គការជំនួយកុមារដើម្បីការរួបរួម និងការចូលរួម (CAMP) សមាគមន៍កុមារកម្ពុជាប្រឆាំងទុរភិក្ស និងហិង្សា (CCASVA) សមាគមន៍ជនជាតិខ្មែរអ៊ីស្លាមដើម្បីសិទ្ធិមនុស្ស និងការអភិវឌ្ឍន៍(CHIMHRDA) អនុវត្តកម្មវិធីអំពើហិង្សា ការរំលោភ និងកេងប្រវ័ញ្ចផ្លូវភេទ។

***<u>សំណួរទី ៣៦</u> : ចូរពិពណ៌នាពីការគាំទ្រផ្តល់ដោយរដ្ឋាភិបាលសម្រាប់សកម្មភាពទាំងនោះ និងការខំប្រឹងប្រែងក្នុងការសម្របសម្រួលរវាងសង្គមស៊ីវិល និងរដ្ឋាភិបាល។***

***<u>ចម្លើយ:</u>*** ជាទូទៅ រដ្ឋាភិបាលជួយសម្របសម្រួលដល់គ្រប់អង្គការដែលមកធ្វើការនៅប្រទេសកម្ពុជា ដោយអនុញ្ញាតឱ្យនាំចូលសំភារៈបរិក្ខារសម្រាប់ធ្វើសកម្មភាព ដោយរដ្ឋាភិបាលចេញការបង់ពន្ធជំនួស ហើយទិដ្ឋាការត្រូវបានផ្តល់ឱ្យដោយពុំគិតថ្លៃចំពោះបុគ្គលិកបរទេស។

កន្លងមកអាជ្ញាធរមានសមត្ថកិច្ច បានសម្របសម្រួលដល់អង្គការក្រៅរដ្ឋាភិបាល ដោយអនុញ្ញាតឱ្យសាងសង់មជ្ឈមណ្ឌលសង្គ្រោះ ឬការអនុវត្តកម្មវិធីផ្សេងៗនៅលើទឹកដីដែលស្ថាប័នទាំងនោះគ្រប់គ្រង។ ទន្ទឹមនោះដែរ ក៏មានការ

ចូលរួមសហការពីស្ថាប័នមានសមត្ថកិច្ច និងក្រសួងពាក់ព័ន្ធទៅលើការងារដែលទាក់ទងព្រឹត្តិការណ៍ទាក់ទាញមតិគាំទ្រ និងការជួយសង្គ្រោះកុមាររងគ្រោះចេញពីផ្ទះបន ។

ការប្រាស្រ័យទាក់ទងរវាងអង្គការក្រៅរដ្ឋាភិបាល និងសមត្ថកិច្ចនៅខេត្ត-ក្រុងមានលក្ខណៈល្អប្រសើរដោយរដ្ឋាភិបាលជំរុញឱ្យមានគណៈកម្មការការពារសិទ្ធិកុមារដែលជាគណៈកម្មការអន្តរផ្នែកមានតួនាទីសម្របសម្រួលការងារកុមារនៅថ្នាក់ខេត្ត-ក្រុង ។

***<u>សំណួរទី ៣៧</u> : ចូរពិពណ៌នាពីតួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយ ក្នុងការឆ្លើយតបនឹងអំពើហិង្សាលើកុមារ ។***

**<u>ចម្លើយ</u> :** ប្រព័ន្ធផ្សព្វផ្សាយនៅក្នុងព្រះរាជាណាចក្រកម្ពុជាមាន ស្ថានីយទូរទស្សន៍ វិទ្យុ សារព័ត៌មាន ព្រឹត្តិបត្រ និងទស្សនាវដ្តី ។ ប្រពន្ធ័ផ្សព្វផ្សាយទាំងនេះមានតួនាទីធ្វើការផ្សព្វផ្សាយព័ត៌មាននានាដូចជា នយោបាយ សេដ្ឋកិច្ច វប្បធម៌ សន្តិសុខ ច្បាប់ទម្លាប់ និងការងារសង្គម ។ល ។ ការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយតាមប្រពន្ធ័ផ្សព្វផ្សាយទាំងនោះ មានបន្ថែមទាំងសារព័ត៌មាន ផ្ទាំងរូបភាព សៀវភៅផ្ទត់ ផងដែរ ។

## IV. កុមារជាសកម្មជនក្នុងការដោះស្រាយអំពើហិង្សា

***<u>សំណួរទី ៣៨</u> : ចូរផ្តល់ព័ត៌មានស្តីពីការចូលរួម និងពិគ្រោះយោបល់ជាមួយកុមារ ក្នុងការរៀបចំសកម្មភាព និងការអនុវត្ត ត្រួតពិនិត្យតាមដានទូវកម្មវិធី គោលនយោបាយ ដើម្បីឆ្លើយតបទៅនឹងអំពើហិង្សាលើពួកគេ ។ ចូរផ្តល់ព័ត៌មានលម្អិត រួមមានអាយុ និងភាពលម្អិតផ្សេងទៀតនៃកុមារដែលចូលរួម ។***

**<u>ចម្លើយ</u> :** កុមារត្រូវបានផ្តល់ឱកាសឱ្យចូលរួមក្នុងព្រឹត្តិការណ៍ និងកម្មវិធីផ្សេងៗជាច្រើន ដែលរៀបចំឡើងដោយស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ជាអាទិ៍មានៈ

- កុមារបានចូលរួមទិវាកុមារអន្តរជាតិ ១មិថុនា រៀងរាល់ឆ្នាំ ដែលរៀបចំដោយរាជរដ្ឋាភិបាល និងមានការរួមចំណែកពីអង្គការនានាផងដែរ ។

- វេទិកាកុមារលើកកម្ពស់ការយល់ដឹងពីសិទ្ធិ និងការចូលរួមមតិរបស់កុមារ ឆ្នាំ២០០២ ក្នុង៦ខេត្ត-ក្រុង ដែលអ្នកចូលរួមជាកុមារក្នុងមជ្ឈមណ្ឌលសង្គ្រោះ និងជាសិស្សសាលា ដែលមានអាយុពី១២ ដល់១៨ឆ្នាំ ។

- វេទិកាជាតិស្តីពី ការលើកកម្ពស់សកម្មភាពការប្រឆាំងការជួញដូរនៅកម្ពុជា ឆ្នាំ២០០៤ ដែលមានសិក្ខាកាមជាកុមារធ្លាប់រងគ្រោះដោយការជួញដូរ និងជាសកម្មជនដើម្បីសិទ្ធិកុមារ មានអាយុពី១២ ដល់ ១៨ឆ្នាំ ។ ពួកគេជាអ្នកសម្របសម្រួល និងពិភាក្សាគ្នាដោយមានការគាំទ្រពីមនុស្សពេញវ័យ ។ អនុសាសន៍ជាច្រើនដែលពួកគេបានលើកឡើងត្រូវបានពិចារណាដើម្បីបញ្ចូលទៅក្នុងផែនការជាតិថ្មី ។ កុមារសិក្ខាកាមទាំងអស់នោះ បានជ្រើសរើសតំណាងរបស់ខ្លួនចំនួន៥រូប ដើម្បីទៅចូលរួមវេទិកាកុមារនៃមហាអនុតំបន់ទន្លេមេគង្គ នៅទីក្រុងបាងកក (ព្រះរាជាណាចក្រថៃឡង់ដ៏) ក្នុងខែតុលា ឆ្នាំ២០០៤ ។

- កុមារធ្លាប់រងគ្រោះដោយសារការកេងប្រវ័ញ្ចផ្លូវភេទចំនួន៣០នាក់ និងកុមារតំណាងពីក្លឹបកុមារ និងយុវជនចំនួន១០នាក់ បានចូលរួមសិក្ខាសាលា ដែលរៀបចំឡើងដោយសម្ព័ន្ធអង្គការដើម្បីឆ្លើយតបនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅកម្ពុជា ដើម្បីលើកជាអនុសាសន៍លើបញ្ហាជួញដូរផ្លូវភេទ សម្រាប់ពិចារណាដាក់បញ្ចូលក្នុងផែនការជាតិថ្មី។

- ពាក់ព័ន្ធនឹងប្រធានបទស្តីពីអំពើហិង្សាលើកុមារ នៅឆ្នាំ២០០៣ សន្និសីទកុមារថ្នាក់ជាតិ ត្រូវបានរៀបចំឡើងដោយ គណៈកម្មាធិការកុមារស្តីពី "ប្រឆាំងអំពើហិង្សាលើកុមារ"។ នៅឆ្នាំ២០០៥ កុមារចំនួន២២៥នាក់ បានចូលរួមកិច្ចពិគ្រោះយោបល់ថ្នាក់ខេត្ត-ក្រុងចំនួន១៥ ក្នុងនោះតំណាងកុមារចំនួន៣០នាក់ បានចូលរួមវេទិកានៅថ្នាក់ជាតិ និងវេទិកាមនុស្សពេញវ័យនៅភ្នំពេញ និងកុមារមួយចំនួនបានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់តំបន់នៅបាងកក(ថៃឡង់ដ៍) ក្នុងខែ មិថុនា ឆ្នាំដដែល។

- តំណាងកុមារ២រូប បានចូលរួមក្នុងសិក្ខាសាលារៀបចំផែនការជាតិ ប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ នៅឆ្នាំ២០០៥។

- ក្រសួងទេសចរណ៍ បានបង្កើតគណៈកម្មាធិការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ (ក.ស.ក.ទ) ដែលមានកម្រិតថ្នាក់ជាតិ និងខេត្ត-ក្រុង ហើយក៏មានការចូលរួមពីអង្គការជំនួយកុមារសម្រាប់ធ្វើការបង្ហាត់បុគ្គលិក មន្ត្រីក្រសួងពាក់ព័ន្ធនឹងវិស័យទេសចរ ព្រមទាំងអ្នកប្រកបអាជីវកម្មបំរើឱ្យអ្នកធ្វើដំណើរទេសចរយល់ដឹង និងចេះនូវវិធីការពារ និងទប់ស្កាត់ការជួញដូរកុមារក្នុងវិស័យទេសចរ។

***<u>សំណួរទី ៣៩</u> : បើសិនជាមាន ចូរពិពណ៌នាពីការចូលរួមរបស់កុមារក្នុងការតាក់តែងនីតិវិធីពិសេស ឬ វិធានភស្តុតាងពិសេស ដែលអនុវត្តនៅក្នុងដំណើរការតុលាការទាក់ទងនឹងអំពើហិង្សាលើកុមារ។ ចូរផ្តល់ព័ត៌មានលម្អិត រាប់ទាំងអាយុ ភាពលម្អិតផ្សេងទៀតទាក់ទងនឹងកុមារចូលរួម។***

***<u>ចម្លើយ</u>*** : ថ្វីបើកុមារមិនបានចូលរួមក្នុងការតាក់តែងនីតិវិធីពិសេសដោយផ្ទាល់ ប៉ុន្តែកុមារបានចូលរួមមតិដើម្បីកសាងគោលនយោបាយ ផែនការ ដូចបានរៀបរាប់ក្នុងសំណួរទី៣៨ ហើយក៏មានកុមាររងគ្រោះ បានផ្តល់ចម្លើយ និងធ្វើជាសាក្សីនៅក្នុងតុលាការផងដែរ។

***<u>សំណួរទី ៤០</u>: ចូរពិពណ៌នាពីចំនួន និងប្រភេទធនធានដែលមានសម្រាប់ទ្រទ្រង់ការចូលរួមរបស់កុមារក្នុងសកម្មភាព ដើម្បីឆ្លើយតបនឹងអំពើហិង្សាលើកុមារ។***

***<u>ចម្លើយ</u>*** : មានការឧបត្ថម្ភគាំទ្រផ្នែកថវិកា ធនធាន និងបច្ចេកទេសដល់សកម្មភាពចូលរួមរបស់កុមារប្រឆាំងអំពើហឹង្សា និងសម្រាប់ការងារសិទ្ធិកុមារពីខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី និងអង្គការនានា និងសប្បុរសជន។

បច្ចុប្បន្ន យើងខ្ញុំពុំទាន់មានយន្តការណាមួយដើម្បីដកស្រង់ស្ថិតិស្តីពីចំនួនថវិកា និងប្រភេទធនធាននេះឱ្យបានច្បាស់លាស់នៅឡើយ ។

## V. គោលនយោបាយ និងកម្មវិធីដើម្បីដោះស្រាយអំពើហិង្សាលើកុមារ

***<u>សំណួរទី ៤១</u> : តើរដ្ឋាភិបាលមានគោលនយោបាយងាយយល់ទាក់ទងនឹងអំពើហិង្សាលើកុមារដែរឬទេ? បើមាន ចូរផ្ដល់ព័ត៌មានលម្អិត និងពណ៌នាពីវិធានយេនឌ័រពិសេស រាប់ទាំងគោលនយោបាយ ។***

**<u>ចម្លើយ</u> :** កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៣នៃរដ្ឋសភា ត្រង់ចំណុច៦៦ បានចែងយ៉ាងច្បាស់ក្នុងគោលនយោបាយរបស់រដ្ឋាភិបាល ដែលទាក់ទងនឹងការគោរពសិទ្ធិ និងការអភិវឌ្ឍកុមារ រួមទាំងការទប់ស្កាត់អំពើហិង្សាលើកុមារផងដែរ។ គោលនយោបាយរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធយេនឌ័រ មានចែងនៅក្នុងគោលនយោបាយត្រង់ចំណុច៦៥ ដែលបានបង្ហាញអំពីការលើកកម្ពស់តួនាទី និងស្ថានភាពស្ត្រី ដោយយកចិត្តទុកដាក់ជំរុញការអនុវត្តយុទ្ធសាស្ត្រយេនឌ័រ កសាងសមត្ថភាពស្ត្រី កែប្រែឥរិយាបថសង្គម ដែលបង្កឱ្យមានភាពរើសអើងចំពោះស្ត្រីភេទអំពើហិង្សាគ្រប់រូបភាព ឱ្យស្ត្រីទទួលបាននូវកិច្ចការពារតាមផ្លូវច្បាប់ ដើម្បីធានាសមភាពរវាងបុរស និងស្ត្រី ព្រមទាំងជួយស្ត្រីឱ្យរួចផុតពីអំពើហិង្សាក្នុងគ្រួសារ និងការជួញដូរភេទ។ ទន្ទឹមនឹងនេះ យុទ្ធសាស្ត្រចតុកោណរបស់សម្ដេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ក៏បានឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីការកសាងធនធានមនុស្ស រួមទាំងកុមារ និងស្ត្រីផងដែរ (ឯកសារជូនភ្ជាប់)។

ថ្មីៗនេះក្រសួងមហាផ្ទៃ បានចេញផែនការ ០២៣ ជ.ក ចុះថ្ងៃទី១៣ កក្កដា ២០០៥ ក្នុងទិសដៅធ្វើសកម្មភាពក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ការរត់ពន្ធមនុស្ស ការធ្វើអាជីវកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ហើយផែនការនេះត្រូវបានផ្សព្វផ្សាយទូទាំងប្រទេសរួចហើយ។

ក្រសួងកិច្ចការនារី មានយុទ្ធសាស្ត្ររយៈពេលប្រាំឆ្នាំ **"នារីរតនៈទី២"** ក្នុងគោលបំណងលើកកម្ពស់តួនាទីស្ត្រីនៅក្នុងសង្គម។ ជាទូទៅ ស្ត្រី និងកុមារី តែងតែជាមុខសញ្ញារងគ្រោះ នៃអំពើហិង្សាក្នុងគ្រួសារ ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ ក្រសួងបានតាំងចិត្តថានឹងលើកកម្ពស់សិទ្ធិស្ត្រី និង ជួយពួកគេឱ្យមានតួនាទីយ៉ាងសំខាន់នៅក្នុងគ្រួសារ និងសង្គម ដោយផ្ដោតផងដែរទៅលើការទទួលបាននូវសិទ្ធិការពារដោយច្បាប់។

ពាក់ព័ន្ធនឹងអំពើហិង្សានៅសាលារៀន ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំគម្រោងប្រាំសម្រាប់វិស័យអប់រំ ២០០៤-២០០៨។ យោងតាមគម្រោងនេះ មានយុទ្ធសាស្ត្រខ្លះ រួមចំណែកដោយប្រយោលទៅនឹងការទប់ទល់អំពើហិង្សាលើកុមារនៅក្នុងសាលារៀន ដែលមានដូចខាងក្រោម :

- ទីមួយ **Child Center Approach** : ជាទូទៅ គ្រូតែងតែមានការងារច្រើនជាងសិស្ស តែយុទ្ធសាស្ត្រនេះលើកទឹកចិត្តឱ្យកុមារធ្វើការច្រើនជាងគ្រូបង្រៀន ដែលជាហេតុនាំឱ្យពួកគេអាចចែករំលែកគំនិតរវាងគ្នានឹងគ្នា និងមានការសហការគ្នាក្នុងឋានៈជាមិត្តភាពរវាងសិស្ស និងសិស្ស។ នៅពេលដែលពួកគេរឹតតែធ្វើការរួមគ្នា ពួកគេនឹងមានស្មារតីសាមគ្គី ដែលធ្វើឱ្យអំពើហិង្សារវាងកុមារ និងកុមារត្រូវបានកាត់បន្ថយ។

- ទីពីរ យុទ្ធសាស្ត្រ**សាលាកុមារមេត្រី** : គោលនយោបាយនេះមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវអារម្មណ៍ល្អរបស់កុមារចំពោះសាលារៀន គឺគោលនយោបាយនេះកំណត់ឱ្យគ្រូត្រូវតែបង្កើនឱ្យមានបរិយាកាសល្អ និងបញ្ចុះបញ្ចូលកុមារឱ្យយល់ថា សាលាជាកន្លែងល្អជាងគេបំផុតក្នុងការសេពគប់។

- សិទ្ធិកុមារ និងសិទ្ធិមនុស្ស ត្រូវបានបញ្ចូលទៅក្នុងកម្មវិធីសិក្សាថ្នាក់ជាតិ។ សិស្សអាចមានគំនិតខ្លះទាក់ទងនឹងសិទ្ធិរបស់ពួកគេ ចាប់ពីថ្នាក់ទីបីមក។

ចំពោះការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ កម្ពុជាមានផែនការជាតិប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ (២០០០-២០០៤) ដែលមាន៤ផ្នែកសំខាន់ៗគឺ : កិច្ចបង្ការទប់ស្កាត់ កិច្ចការពារ ការស្តារ និងអភិវឌ្ឍសមត្ថភាព និងសមាហរណកម្មទៅក្នុងសហគមន៍។ ដោយផែនការនេះបានចប់អណ្តត្តិរបស់ខ្លួន ក្រុមប្រឹក្សាជាតិដើម្បីកុមារ កំពុងរៀបចំព្រាងផែនការជាតិទី២។

បណ្តាញការពារកុមារក្នុងសហគមន៍ ត្រូវបានបង្កើតឡើងដោយមានការគាំទ្រពីអង្គការយូនីសេហ្វ នៅខេត្តបន្ទាយមានជ័យ បាត់ដំបង ព្រៃវែង ស្វាយរៀង និងភ្នំពេញ។ បណ្តាសហគមន៍ មានដូចជាអ្នកស្ម័គ្រចិត្តសង្គមកិច្ចភូមិ គ្រូបង្រៀន លោកសង្ឃ អ្នកធ្វើការផ្នែកសុខភាព និងអ្នកធ្វើការខាងសង្គម នៅថ្នាក់ស្រុកត្រូវបានបង្កើតឡើង ក្នុងគោលបំណងទប់ស្កាត់ការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងដើម្បីធានាការឃ្លាំមើលករណីដែលសង្ស័យ និងឱ្យកុមាររងគ្រោះទទួលបានសេវាល្អ។ នៅពេលនេះគម្រោងការសាកល្បងត្រូវបានរើសដាក់បញ្ចូលទៅក្នុងគម្រោងការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងផ្តោតលើការបង្កើនការទទួលបាននូវសេវាសំខាន់ៗតាមសហគមន៍។

***<u>សំណួរទី៤២</u>: តើរដ្ឋាភិបាលបានបញ្ជូន ឬ ផ្តល់ការគាំទ្រទៅភ្នាក់ងារផ្សេងទៀត សម្រាប់ការបញ្ជូនកម្មវិធីពិសេស ដើម្បីទប់ស្កាត់ និងឆ្លើយតបនឹងអំពើហិង្សាលើកុមារ?***

***បើសិនជាមាន ចូរផ្តល់របាយការណ៍លម្អិត ឬ ទីតាំងឯកសារនៅលើអ៊ិនធើណេតUniform Resources Locater (URLs) នៃកម្មវិធីទាំងនេះ និងដោយប្រើប្រាស់តារាងខាងក្រោម បង្ហាញថាក្នុងក្របខ័ណ្ឌណា និងប្រភេទអំពើហិង្សាណាត្រូវបានសរសេរក្នុងកម្មវិធីនេះ។***

***<u>ចម្លើយ</u>:*** បណ្តាញការពារកុមារនៅសហគមន៍ដែលបានរៀបរាប់ពីខាងលើ ហើយដែលបានទទួលការគាំទ្រពីអង្គការយូនីសេហ្វ មានបំណងបង្ការទប់ស្កាត់ និងបញ្ជូនករណីកុមារដែលរងគ្រោះដោយការរំលោភបំពាន ការកេង ប្រវ័ញ្ច និងការជួញដូរ ដោយរួមមានទាំងអំពើហិង្សាលើកុមារផងដែរទៅកាន់សេវាសមស្រប ដូចជាបញ្ជូនទៅឱ្យនគរ បាល មន្ទីរពេទ្យ ឬសេវាស្តារនីតិសម្បទារបស់រដ្ឋ និងរបស់អង្គការក្រៅរដ្ឋាភិបាលជាដើម។ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ធ្វើការឆ្លើយតបទៅនឹងករណីទាំងអស់នោះតាមរយៈការរាយការណ៍ និងការស៊ើបអង្កេតឃាត់ខ្លួនជន ល្មើស និងបញ្ជូនជនរងគ្រោះទៅសេវាសមស្រប ឬទៅគ្រួសារវិញ។

កម្ពុជាមិនទាន់មានទីតាំងប្រព័ន្ធឯកសារ នៅលើអ៊ិនធឺណេតនៅឡើយទេ។

| | រូបរាងកាយ | ផ្លូវភេទ | ស្មារតី ចិត្ត | ការធ្វេសប្រហែស | HTTPs | ផ្សេងៗ |
|---|---|---|---|---|---|---|
| គ្រួសារ ផ្ទះ | √ | √ | √ | √ | | |
| សាលារៀន | មិនទាន់មាន ប្រភពច្បាស់ | មិនទាន់មាន ប្រភពច្បាស់ | មិនទាន់មាន ប្រភពច្បាស់ | មិនទាន់មាន ប្រភពច្បាស់ | មិនទាន់មាន ប្រភពច្បាស់ | |

| | | | | | | |
|---|---|---|---|---|---|---|
| | លាស់ | លាស់ | លាស់ | លាស់ | លាស់ | |
| មជ្ឈមណ្ឌលអប់រំ | មិនទាន់មានប្រភពច្បាស់លាស់ | មិនទាន់មានប្រភពច្បាស់លាស់ | មិនទាន់មានប្រភពច្បាស់លាស់ | មិនទាន់មានប្រភពច្បាស់លាស់ | មិនទាន់មានប្រភពច្បាស់លាស់ | |
| អ្នកជិតខាងសហគមន៍ | √ | √ | √ | √ | មិនទាន់មានប្រភពច្បាស់លាស់ | |
| កន្លែងធ្វើការ | មិនទាន់មានប្រភពច្បាស់លាស់ | មិនទាន់មានប្រភពច្បាស់លាស់ | មិនទាន់មានប្រភពច្បាស់លាស់ | មិនទាន់មានប្រភពច្បាស់លាស់ | មិនទាន់មានប្រភពច្បាស់លាស់ | |
| ការអនុវត្តច្បាប់ | √ | √ | មិនទាន់មានប្រភពច្បាស់លាស់ | √ | មិនទាន់មានប្រភពច្បាស់លាស់ | |
| ផ្សេងៗ | | | | | | |

***សំណួរទី ៤៣*** ***: តើរដ្ឋាភិបាលអ្នក ធ្វើការពិនិត្យតាមដានអំពីផលប៉ះពាល់នៃគោលនយោបាយ និងកម្មវិធីទប់ស្កាត់អំពើហិង្សាលើកុមារដែរឬទេ?***

***បើសិនជាមាន ចូរពិពណ៌នាពីប្រព័ន្ធត្រួតពិនិត្យ និងផ្តល់ទីតាំងឯកសារនៅលើអ៊ិនធើណេត Uniform Resources Locater (URL) ឬ របស់យោងផ្សេងទៀត ដែលក្នុងនោះប្រព័ន្ធ និងលទ្ធផលត្រូវបាននិយាយដោយ លម្អិតបំផុត ។***

***ចម្លើយ*** : ទាក់ទងនឹងការជួញដូរមនុស្ស និងកេងប្រវ័ញ្ចផ្លូវភេទ បច្ចុប្បន្ន ការប៉ាន់ប្រមាណអំពីផលប៉ះពាល់នៃគោលនយោបាយ និងកម្មវិធីនៅមានកម្រិត។ ដើម្បីបង្កើនការយល់ដឹងពីផលប៉ះពាល់នៃគោលនយោបាយ ការពិនិត្យតាមដាន និងវាយតម្លៃគឺជាសមាសភាគដ៏សំខាន់នៅគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធកម្មវិធីនយោបាយទាំងអស់។ ប្រព័ន្ធគ្រប់គ្រងព័ត៌មានមួយកំពុងត្រូវបានបង្កើតឡើងនៅតាមក្រសួងពាក់ព័ន្ធខ្លះៗ ដើម្បីប្រមូល បូកសរុប និងផ្សព្វផ្សាយព័ត៌មានស្តីពីកិច្ចការពារកុមារ ដែលរួមមានទាំងអំពើហិង្សាបញ្ហាផ្សេងៗ គោលនយោបាយ និងកម្មវិធីផងដែរ។

***សំណួរទី ៤៤*** ***: តើរដ្ឋាភិបាលបានចូលរួមក្នុងសកម្មភាពសម្របសម្រួលជាអន្តរជាតិ ទាក់ទងនឹងអំពើហិង្សាលើកុមារដែរឬទេ? បើសិនជាមាន ចូរផ្តល់ព័ត៌មានលម្អិត។***

***ចម្លើយ*** :

ប្រទេសកម្ពុជា បានចុះហត្ថលេខាលើ សន្ធិសញ្ញាស្តីពីបត្យាប័ន អនុស្សារណៈយោគយល់គ្នា និងបានសហការជាមួយប្រទេសជិតខាងដូចមាន :

- បានចុះហត្ថលេខាលើសន្ធិសញ្ញាស្តីពីបត្យាប័នជាមួយប្រទេសឡាវ ថៃ និងចិន។
- បានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នារវាងប្រទេសកម្ពុជា និងថៃ នៅឆ្នាំ២០០៣ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ក្នុងការលុបបំបាត់ការជួញដូរកុមារ និងស្ត្រី និងជួយដល់ជនរងគ្រោះដោយសារការជួញដូរ។

- បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងប្រទេសកម្ពុជា និងវៀតណាម នៅខែតុលា ឆ្នាំ២០០៥ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរស្ត្រី និងកុមារ និងជួយដល់ជនរងគ្រោះដោយសារការជួញដូរ ហើយក៏កំពុងរៀបចំ ធ្វើជាមួយប្រទេសម៉ាឡេស៊ីដែរ ។

- កំឡុងពេលកិច្ចប្រជុំកំពូលអាស៊ានលើកទី៨ នៅទីក្រុងភ្នំពេញ ថ្ងៃទី៤-៥ វិច្ឆិកា ឆ្នាំ២០០២ មេដឹកនាំអាស៊ាន រាប់ទាំងកម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមេមួយ ស្តីពីកិច្ចសហប្រតិបត្តិការអាស៊ានលើវិស័យទេសចរណ៍ ដែលមានបញ្ញត្តិទូទៅ ដូចជា វិធានការត្រូវធ្វើដើម្បីចៀសវាងការរំលោភណាមួយក្នុងវិស័យទេសចណ៍ទៅលើមរតកវប្បធម៌ និងធនធានធម្មជាតិនៃប្រទេសក្នុងតំបន់ ជាពិសេសការកេងប្រវ័ញ្ចលើស្ត្រី និងកុមារ ។

- បានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នា លើកិច្ចសហប្រតិបត្តិការមួយរវាងប្រទេសមហាអនុតំបន់ទន្លេមេគង្គ ដែលអនុវត្តកម្មវិធីស្តីពីការសម្របសម្រួលគំនិតផ្តួចផ្តើមថ្នាក់រដ្ឋមន្ត្រីប្រឆាំងអំពើជួញដូរមនុស្ស(COMMIT) ដើម្បីឆ្លើយតបទៅនឹងការជួញដូរមនុស្ស។ ប្រទេសកម្ពុជា បានបង្កើតក្រុមការងារថ្នាក់ជាតិមួយសម្រាប់ទទួលការងារនេះ ។

- បានចូលរួមអនុម័ត សេចក្តីព្រាងដំណោះស្រាយស្តីពី ការគាំពារ និងការលុបបំបាត់ទម្រង់អាក្រក់របស់ការងារកុមារ នៅក្នុងមហាសន្និបាតលើកទី២៥របស់អង្គការអន្តរសភាអាស៊ាន (AIPO) កាលពីខែ កញ្ញា ឆ្នាំ២០០៤។

- បានចូលរួមអនុម័តសេចក្តីប្រកាសសៀមរាប-អង្គរ មានឈ្មោះថា*ឆ្ពោះទៅរកតំបន់មួយដែលគិតគូរកុមារគ្រប់រូប* នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់រដ្ឋមន្ត្រីលើកទី៧ ស្តីពីកុមារតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក នៅខែមិនា ឆ្នាំ២០០៥។ សេចក្តីប្រកាសនេះបានកំណត់នូវបញ្ហាសំខាន់៧ និងលើកឡើងនូវគោលការណ៍នៃសកម្មភាព ដែលក្នុងនោះក៏បានទទួលស្គាល់នូវតម្រូវការ ដើម្បីដោះស្រាយអំពើហិង្សាលើកុមារ និងចូលរួមនៅក្នុងការសិក្សារបស់អគ្គលេខាធិការនៃ អ.ស.ប ស្តីពី អំពើហិង្សាលើកុមារ ។

## VI. ការប្រមូលទិន្នន័យ វិភាគ និងការស្រាវជ្រាវ

ប្រធានបទដែលបានសួរនៅជំពូកទី៦ដែលពាក់ព័ន្ធនឹងសំណួរទី៤៥, ៤៦, ៤៧, ៤៨, ៤៩, ៥០, ៥១, ៥២, ៥៣ កម្ពុជាមិនទាន់មានប្រព័ន្ធមូលដ្ឋានទិន្ន័យសម្រាប់ប្រមូលទិន្ន័យធ្វើការវិភាគ និងស្រាវជ្រាវណាមួយដែលបានបង្ហាញពីលទ្ធផលច្បាស់ លាស់នឹងយកជាផ្លូវការបាននៅឡើយទេ ។

## VII. ការយល់ដឹង ការទាក់ទាញមតិគាំទ្រ និងការបណ្តុះបណ្តាល

***<u>សំណួរទី ៥៤</u>: ប្រាំឆ្នាំកន្លងមក តើរដ្ឋាភិបាលបានដឹកនាំ ឬ ដាក់បន្ទុកឱ្យមានយុទ្ធនាការដើម្បីលើកកម្ពស់ចំណេះដឹងទាក់ទងនឹងការការពារអំពើហិង្សាលើកុមារដែរឬទេ ។***

***បើមាន ចូរពិពណ៌នាពីយុទ្ធនាការថ្មីៗនេះ រាប់ទាំងក្របខ័ណ្ឌ និងប្រភេទនៃអំពើហិង្សាដែលជាប្រធានបទនៃយុទ្ធនាការ និងសាធារណជនដែលជាគោលដៅ (សាធារណជនទូទៅ អ្នកផ្តល់ការថែទាំ គ្រូ ។ល ។)***

***ចម្លើយ*** **:** ជារៀងរាល់ឆ្នាំ ក.ជ.ក.ក និងក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល និងកុមារ បានរៀបចំទិវាកុមារអន្តរជាតិ ១ មិថុនា និងទិវាពិភពលោកប្រឆាំងពលកម្មកុមារទូទាំងព្រះរាជាណាចក្រកម្ពុជា។ ប្រធានបទនៃទិវាកុមារនៅ ឆ្នាំ២០០៥ គឺ *ប្រឆាំងអំពើហិង្សាលើកុមារ*។ យុទ្ធនាការនេះ មានទិសដៅលើកកម្ពស់ការយល់ដឹងដល់មន្ត្រីរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ សាធារណជន និងកុមារ អំពីសិទ្ធិ និងបញ្ហារបស់កុមារ ពិសេសអំពើហិង្សា រួមទាំងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។

ដោយឡែក ក្រសួងកិច្ចការនារី បានសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលរៀបចំយុទ្ធនាការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ "បូពណ៌ស" នៅទីក្រុងភ្នំពេញ និងខេត្តនានា ក្នុងគោលបំណងលុបបំបាត់អំពើហិង្សាលើស្ត្រី និងកុមារ។

ចាប់ពីឆ្នាំ២000 ដល់២០០៥ ចំពោះគម្រោងទប់ស្កាត់រាល់ទម្រង់នៃការជួញដូរមនុស្ស ក្រសួងបានសហការជាមួយអង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) ក្នុងនោះមានការជួយឧបត្ថម្ភថវិកាពីក្រសួងការបរទេស នៃរាជរដ្ឋាភិបាលហ្វាំងឡង់ និងអង្គការ (USAID) ធ្វើយុទ្ធនាការផ្សព្វផ្សាយព័ត៌មាន បាន១៩ខេត្ត-ក្រុង ដែលមានប្រជាជនចូលរួមប្រមាណបីរយពាន់នាក់(៣00.000នាក់) ក្រៅពីការផ្សព្វផ្សាយព័ត៌មានក្រុមការងាររបស់ក្រសួង បានបណ្តុះបណ្តាលផ្នែកច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងការធ្វើអាជីវកម្មលើមនុស្សដល់អាជ្ញាធរដែនដី ក្រុមប្រឹក្សាឃុំ-សង្កាត់ អភិបាលស្រុក អធិការនគរបាលស្រុក មេប៉ុស្តិ៍តាមឃុំ នាយកវិទ្យាល័យ បាន១៩ ខេត្ត-ក្រុង ដែលមានសិក្ខាកាមចូលរួមចំនួនបួនពាន់នាក់ (៤.000នាក់)។

ក្រសួងមហាផ្ទៃ បានផលិតវីដេអូស្តីពី " **ជនរងគ្រោះ** " ដែលត្រូវបានចាប់បញ្ចូលទៅក្នុងកម្មវិធីបង្រៀនសម្រាប់ប៉ូលីស តាមរយៈគម្រោង LEASETC ដែលបានផ្សាយតាមបណ្តាញទូរទស្សន៍ពេញប្រទេស។ យុទ្ធនាការផ្សព្វផ្សាយគ្រោះថ្នាក់ដោយអំពើជួញដូរមនុស្សនៅតាមសាលារៀន ដែលកំពុងអនុវត្តនៅរាជធានីភ្នំពេញ ចាប់ពីឆ្នាំ២00៤ និងបន្តធ្វើនៅខេត្ត៣ទៀតគឺ ខេត្តកំពង់ចាម សៀមរាប បន្ទាយមានជ័យ នៅឆ្នាំ២00៦។

ដោយមានការឧបត្ថម្ភគាំទ្រពីអង្គការ ILO/IPEC គណៈកម្មាធិការការពារកុមារនៃខេត្តបាត់ដំបង បន្ទាយមានជ័យ ព្រៃវែង និងក្រុងព្រះសីហនុ បានអនុវត្តគម្រោងការទប់ស្កាត់ការជួញដូរកុមារ និងស្ត្រី។

ដោយមានការគាំទ្រពីអង្គការ UNIAP នាយកដ្ឋានអប់រំក្រៅប្រព័ន្ធរបស់ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើសៀវភៅអប់រំក្រៅប្រព័ន្ធពីរក្បាល ដែលអត្ថន័យផ្តោតទៅលើការលុបបំបាត់ការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទ។ គ្រូបង្វឹកចំនួន ៥៦នាក់ត្រូវបានអញ្ជើញពីខេត្ត និងក្រុងចំនួន៥ ដើម្បីចូលរួមក្នុងសិក្ខាសាលាជាតិ ស្តីពីវិធីសាស្ត្រក្នុងការបង្រៀននៅឆ្នាំ២00២។ គ្រូបង្វឹកទាំង ៥៦នាក់នេះបានយកសៀវភៅចំនួន ៥000ក្បាល ចែកចាយដល់ប្រជាពលរដ្ឋនៅទូទាំងប្រទេស ហើយអ្នកភូមិចំនួន ១២00 នាក់ ត្រូវបានបង្ហាត់បង្រៀន។

គណៈកម្មាធិការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ (គ.ស.ក.ទ) របស់ក្រសួងទេសចរណ៍ មានកិច្ចសហប្រតិបត្តិការជាមួយក្រសួងស្ថាប័ន អង្គការជាតិ និងអន្តរជាតិ ក្នុងសកម្មភាពបណ្តុះបណ្តាល អប់រំដល់ក្រុមគោលដៅផ្ទាល់ និងក្រុមគោលដៅប្រយោល បានសម្រេចលទ្ធផលជាច្រើនបន្តបន្ទាប់។ គ.ស.ក.ទ មានការចូលរួមប្រជុំ ឬសិក្ខាសាលាជា

លក្ខណៈជាតិ និងអន្តរជាតិ ព្រមទាំងបានផលិតសម្ភារៈផ្សព្វផ្សាយដូចជា សៀវភៅផ្ទត់ ខិត្តប័ណ្ណ ប័ណ្ណប្រកាស កូនសៀវភៅតូច ដើម្បីធ្វើការផ្សព្វផ្សាយ ផ្លាកផ្សព្វផ្សាយនៅតាមផ្លូវ និងតំបន់គោលដៅទេសចរណ៍មួយចំនួនស្តីពីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍។

***សំណួរទី ៥៥*** **: តើសារនៃយុទ្ធនាការ និងព័ត៌មានត្រូវបានផ្សាយយ៉ាងដូចម្តេច? (ពិនិត្យមើលតារាងខាងក្រោម)**

***ចម្លើយ:***

| | |
|---|---|
| ប្រព័ន្ធព័ត៌មានបោះពុម្ព | √ |
| វិទ្យុ | √ |
| ទូរទស្សន៍ | √ |
| ល្ខោន | √ |
| សាលារៀន | √ |
| ផ្សេងៗ | √ |

***សំណួរទី ៥៦*** **: ប្រាំឆ្នាំកន្លងមក តើរដ្ឋាភិបាលបានផ្តល់ ឬដាក់បន្ទុកឱ្យគេមានកម្មវិធីបណ្តុះបណ្តាល ទាក់ទងនឹងអំពើហិង្សាលើកុមារដែរឬទេ?**

**បើសិនជាមាន ចូរបង្ហាញថា តើតំបន់ណាត្រូវបានយកចិត្តទុកដាក់ដោយកម្មវិធីបណ្តុះបណ្តាលនេះ និងក្រុមប្រភេទណាដែលទទួលការបណ្តុះបណ្តាល។**

***ចម្លើយ:***

| | កិច្ចបង្ការទប់ស្កាត់ | កិច្ចការពារ | ការធ្វើឱ្យប្រសើរឡើងវិញ | ការស្តារនីតិសម្បទា | ទណ្ឌកម្ម |
|---|---|---|---|---|---|
| អ្នកជំនាញផ្នែកពេទ្យ (រាប់ទាំងពេទ្យកុមារ គិលានុបដ្ឋាក ពេទ្យព្យាបាលមនុស្សឆ្កួត និងពេទ្យធ្មេញ) | √ | √ | √ | √ | √ |
| អ្នកអនុវត្តសុខភាពសាធារណៈ | √ | √ | √ | √ | √ |
| អ្នកធ្វើការផ្នែកសង្គម និងអ្នកចិត្តសាស្ត្រ | √ | √ | √ | √ | √ |
| គ្រូ និងអ្នកអប់រំផ្សេងទៀត | √ | √ | √ | √ | √ |
| មន្ត្រីតុលាការ (រាប់ទាំងតុលាការ) | √ | √ | √ | √ | √ |

| | | | | | |
|---|---|---|---|---|---|
| ប៉ូលីស | √ | √ | √ | | √ |
| មន្ត្រីពន្ធនាគារ | √ | √ | √ | √ | √ |
| មន្ត្រីទទួលបន្ទុកជនល្មើសអនីតិជន មន្ត្រីមជ្ឈមណ្ឌលអប់រំ ឪពុកម្តាយ អាណាព្យាបាល | √ | √ | √ | √ | √ |
| ផ្សេងៗ (សូមបញ្ជាក់ខាងក្រោម) | | | | | |

នៅឆ្នាំ២០០៤ ដោយមានការគាំទ្របច្ចេកទេសពីអង្គការយូនីសេហ្វ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី និងអ្នកជំនាញច្បាប់ បានបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោល អំពីសិទ្ធិកុមារ និងកិច្ចការពារ។ វគ្គដំបូងសម្រាប់សិស្ស មេធាវីត្រូវបានប្រព្រឹត្តទៅនៅខែមិថុនា ឆ្នាំ២០០៥។ ការបណ្តុះបណ្តាលស្រដៀងគ្នានេះនឹងត្រូវធ្វើនៅរាជបណ្ឌិតសភា វិជ្ជាជីវៈតុលាការ ដែលមានដូចខាងក្រោមៈ

- សិទ្ធិកុមារត្រូវបានបញ្ចូលក្នុងកម្មវិធីសិក្សារបស់សាលាចៅក្រម
- ការបណ្តុះបណ្តាលគ្រូបង្គោលចំនួន ៥-៨នាក់ ដែលនឹងត្រូវធ្វើការបណ្តុះបណ្តាលបន្តទៅដល់សិស្ស ចៅក្រម និងព្រះរាជអាជ្ញា
- ការបណ្តុះបណ្តាលដល់ចៅក្រម និងព្រះរាជអាជ្ញា។

~~~~~~~~~~
~~~~~~~~~~